# ការសំភាសន៍ជាលើកទី២របស់អ្នកមីង យ៉ាន៉ ចន្ធូ

កៈ អ្នកដែលសំភាសន៍ឈ្មោះ ញ៉ែម សុគន្ធា          ខៈ អ្នកដែលត្រូវគេសំភាសន៍ យ៉ាន់ ចន្ធូ

## <u>ការសង្ខេបជាលើកទី២របស់អ្នកមីង យ៉ាន៉ ចន្ធូ</u>

អ្នកមីងយ៉ាន់ ចន្ធូ គាត់ពុំបានរៀនអក្សរច្រើនប៉ុន្មានទេ គ្រាន់តែបានរៀនអក្ខរកម្មបន្ទាប់ពីសម័យប៉ុល ពត ព្រោះពេលសង្គ្រាមពុំមានគេអោយរៀន។បន្ទាប់ពីបែកសង្គ្រាមអ្នកមីងបានរៀបការជាមួយស្វាមី ដែលត្រូវជាបងប្អូនដែរ ហើយមានកូន៦នាក់តែស្លាប់អត់ម្នាក់ស្វាមីអ្នកមីងស្លាប់ដោយសារកើតជំងឺទឹកនោមផ្អែម ហើយត្រូវកាត់ជើងដើម្បីរស់បានយូរ។ អ្នកបានរស់នៅក្នុងសង្គ្រាមប៉ុល ពត ហើយត្រូវអត់ឃ្លានហើយមានការភ័យខ្លាចព្រោះខ្លាចគេសម្លាប់ចោល!!សម័យលន់ នល់ គឺត្រូវគេចគ្រាប់ហើយម្ដាយបានជីកត្រង់សេដើម្បីអោយកូននៅក្នុងហ្នឹងអោយរួចផុតពីគ្រាប់មីន។សព្វថ្ងៃអ្នកមីងប្រកបរបបចំការដាំផ្ទីដើម្បីចិញ្ចឹមជីវិត។

កៈ

ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់អ្នកមីងដែលអោយញ៉ុមសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីងជាលើកទី២ នាងខ្ញុំឈ្មោះញ៉ែម សុគន្ធា ជាអ្នកសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីងនៅក្នុងថ្ងៃនេះពួកយើងសំភាសន៍គឺនៅក្នុងខែមិនា ឆ្នាំ២០១៨ ការសំភាសន៍មានទីតាំងស្ថិតនៅក្នុងភូមិកោះគរ ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្ដាល ប្រទេសកម្ពុជា។អ៊ីចឹងពេលមុនអ្នកមីងបានប្រាប់ពីជីវប្រវត្តិរបស់អ្នកមីងខ្លះៗ ប៉ុន្តែនៅមានការសំភាសន៍ជាលើកទី២ទៀតអ៊ីចឹងអ្នកមីងអាចនិយាយរៀបរាប់ពីអ្វីដែលអ្នកមីងចង់ ក៏ដូចជាពួកយើងនិយាយពិភាក្សាគ្នាទៅយើងអាចដឹងអំពីជីវប្រវត្តិរបស់អ្នកមីងបន្ថែមទៀត! អញ្ចឹងអ្នកមីងសូមប្រាប់ឈ្មោះអ្នកមីងម្ដងទៀតមើល!!

ខៈ ញ៉ុមឈ្មោះយ៉ាន់ ចន្ធូ។

កៈ អ្នកមីងចូលដល់ការសិក្សារបស់អ្នកមីង អ្នកមីងរៀនបានថ្នាក់ទីប៉ុន្មានដែរ?

ខៈ អត់មានថ្នាក់ទេ ដូចញ៉ុមនិយាយអ៊ីចឹង!!

កៈចាំ!!

ខៈនៅជំនាន់អាពតគេបង្រៀននៅក្រោមដើមស្វាយហាំ
រៀនថ្ងៃត្រង់មួយភ្លេតៗហ្នឹងហើយដល់ម៉ោងទៅវែកដីវែកដី ដល់ម៉ោងស្ទូងស្រូវស្ទូងស្រូវ!!

កៈចាំ!!

ខៈ
ដល់ម៉ោងដកសំណាបដកសំណាបហើយរៀនអាពេលយើងឈប់មួយភ្លេតៗអាពេលថ្ងៃត្រង់តិចហ្នឹងក្រោមដើមស្វាយហ្នឹង!!

កៈចាំ!!

ខៈហើយដល់ពេលញ៉ុមការហើយ ញ៉ុមការហើយ៧៩(១៩៧៩)
ហើយដល់ហើយទៅមានគ្រូយើងគេអោយរៀនអក្ខរកម្មហ្នំ!!

កៈចាំ!!

ខៈញ៉ុមបានរៀនអក្ខរកម្មប្រលងជាប់
ប្រលងជាប់អក្ខរកម្មបានញ៉ុមបានចេះខ្លះប៉ុន្តែវាខានមើលសៀវភៅខានមើលអីយូរទៅយើងវាភ្លេចភ្លាំងដែរហាំ!!

កៈ តែឥឡូវអ្នកមីងនៅអាចដាច់ទេអ្នកមីងហោ?

ខៈ នៅអានដាច់!!

កៈចាំអញ្ចឹងល្អហើយ!!

ខៈ នៅអានដាច់ហើយញ៉ុមព្យាយាមបន្តិចទៅមើលដាច់ទៅ
មើលមើលកន្លែងណាអត់ចេះញ៉ុមកេសបងឯងសួរអ៊ីចឹងទៅ!!(សួរមិត្តភក្តិ)
ញ៉ុមទៅព្រះវិហារហ្នឹងញ៉ុមមើល មើលដាច់អញ្ចឹងទៅ

ដល់កន្លែងដែលអក្សរពិបាកពេកមានជើងមានដៃច្រើនពេកអញ្ចឹងទៅបងស្អីគេអានេះ បងគាត់ប្រាប់!!ប្រាប់អញ្ចឹងទៅយើងចាំ បើយើងមើលជាប់ទៅយើងចាំ!!

ក៖អីគេអញ្ចឹងទៅ!!

ខ៖ អីគេហើយចាំ!!

ក៖ តែពេលខ្លះមែនហ្នឹងពេលខ្លះអក្សរខ្មែរយើងពេលខ្លះពិបាកអានមែនហ្នឹងហាំ!!!

ខ៖ អាមានជើងផង មានជើង រ ជើង ត អីអានេបអានប់ច្រើនពេកញ៉ុមអានអត់ដាច់ទេ ញ៉ុមសួរបង អាហ្នឹងគេហៅស្អីគេនេះ!!!

ក៖ចាំអញ្ចឹងអ្នកមីងពេលនៅពេល ពេលនៅកំពុងរៀនអីអញ្ចឹង ទោះថាមិនអើរមិនបានរៀនខ្ពស់អីណាស់ណា ត្រឹមតែអក្ខរកម្មខ្ពស់អី តែពីក្មេងមានដែលមានក្តីស្រម៉ៃអីអត់អ្នកមីង?

ខ៖ ញ៉ុមពីក្មេងញ៉ុមអត់ដែលស្រម៉ៃអីផង។

ក៖ហ៊ឺ!

ខ៖ អត់ដែលបានស្រម៉ៃអី ដោយសារយើងអើរនៅជំនាន់ប៉ុល ពតយើងដឹងស្រម៉ៃធ្វើអី បើស្រម៉ៃហ្នឹងបើថាព្រលឹមឡើងយើងដឹងតែរែកដី គ្មានសង្ឃឹមថាបានដូចយើងរាល់ថ្ងៃនេះផងទេ!!

ក៖ ចាំអត់សង្ឃឹមថារស់ផងហី?

ខ៖ចាំអត់សង្ឃឹមថានឹងរស់ផង!!

ក៖ចាំ!!

ខ៖មានក្តីស្រម៉ៃហ្នឹងមកពីណា បើជំនាន់ហ្នឹងយើងអត់មានក្តីស្រម៉ៃទេ !!

ក៖ហ៊ឺៗ!!

ខ៖ដោយសារអក្សរក៏ចេះដឹងមិនបានរៀន តើស្រម៉ៃធ្វើអី
បើស្រម៉ៃថាយើងធ្វើពេទ្យយើងក៏ចេះអក្សរ!!

ក៖ចាំ!!

ខ៖
ហើយក៏គ្មានអ្នកណាយកអ្នកដែលអត់ចេះយកទៅធ្វើម្ល៉ោះហើយយើងជ្រុលថាអត់ចេះហើយ
គ្មានក្ដីស្រម៉ៃអីទេញ៉ុម!!

ក៖ យ៉ាប់ណាស់អ៊ំដល់ពេលបំបិទ
ដល់ពេលមានសង្គ្រាមអ៊ិចឹងទៅបំបិទនូវក្ដីស្រម៉ៃរបស់មនុស្សម្នាក់ៗ ទាំងអស់
អើយយ៉ាប់ណាស់!! ចាំអញ្ចឹងអ៊ំដល់ពេលនៅរៀនអក្ខរកម្មអីវ៉ាន់ហ្នឹងគេរៀនច្រើនអីទេអ៊ំ?

ខ៖ អើររៀននៅក្នុងភូមិយើង
កាលហ្នឹងគេរៀនច្រើនដែរតើ!!តែញ៉ុមរៀននៅសាលាឈូងលៀបហ្នឹងដែរហាំ!!

ក៖ចាំ!!

ខ៖ហ្នឹងនៅក្នុងភូមិយើងហ្នឹង
នៅស្រុករស្រុករយើងហ្នឹងកាលញ៉ុមរៀនហាំ!!ក៖ចាំ!!ខ៖គេអោយយើងរៀនអក្ខរកម្មចាស់ៗ
យើងហ្នឹង!!

ក៖ ប៉ុន្មានឆ្នាំអ៊ំពេលរៀនពេលហ្នឹង?

ខ៖ ដូចរៀងឆាប់ដែរកាលហ្នឹង!!

ក៖ ចាំហើយក៏បានប្រលងបានឈប់រៀនឈប់រៀនដែរទៅ?

ខ៖ បានប្រលងជាប់អញ្ចឹងស្រាប់តែគេឈប់បង្រៀននេះអក្ខរកម្មកាលហ្នឹងហាំ!!បានប្រលង!!

ក៖ ហ្វាំដោយសារនេះទេហីអ៊ំ គេបង្កើតសាលាបង្កើតអីទេហីបានគេបញ្ឈប់អញ្ចឹង?

ខ៖កាលហ្នឹងបង្រៀនសាលាជាមួយក្មេងៗហ្នឹង ក្មេងគេរៀន
ដូចយើងទៅសុំសាលាគេរៀនអញ្ចឹងណាស់!!គេរៀនអក្ខរកម្មហ្នឹងដូចគេចន្លោះក្មេងរៀនអញ្ចឹង
ណាស់!!

ក៖ចាំ!!

ខ៖ ដូចក្មេងរៀនពេលព្រឹកយើងរៀនពេលថ្ងៃទៅណាស់!!

ក៖ គេទៅប្រកាសប្រាប់ថាម៉េចទៅអ៊ំគេដើរប្រកាសប្រាប់តាមភូមិអញ្ចឹងទៅហី?

ខ៖ ចាំ!!ប្រកាសប្រាប់អោយទៅរៀនអក្ខរកម្មអ៊ិចឹងហើយគ្រូ
គ្រូបង្រៀនសិស្សរាល់ថ្ងៃគេបង្រៀនយើងហាំ!!

ក៖ហ្ហំ!!

ខ៖គ្រូបង្រៀនសិស្សហ្នឹងដូចញ៉ុមនិយាយដូចពេលយើងបង្រៀនសិស្សពេលព្រឹកអញ្ចឹង
យើងបង្រៀនអក្ខរកម្មពេលល្ងាចអីអញ្ចឹងទៅណាស់!!

ក៖ហ៊ីៗ!!

ខ៖ម៉ាសាលាអក្ខរកម្មអញ្ចឹងមានម៉ោងមានពេលគេបង្រៀនទៅ
ញ៉ុមទៅរៀនជាមួយគេរាល់តែថ្ងៃហ្នឹង។

ក៖ ក៏បានចេះអានចេះអី!!

ខ៖ ក៏បានចេះអីខ្លះអញ្ចឹងទៅ!!

ក៖ ចាំអញ្ចឹងអ៊ំសំរាប់ចូលដល់ជីវិតអាពាហ៍ពិពាហ៍របស់អ៊ំវិញ
អ៊ំរៀបការជាមួយស្វាមីគាត់ឈ្មោះអីគេដែរអ៊ំ?

ខ៖ គាត់ឈ្មោះថុល កុសល្យ!!

ក៖ ចាំគាត់ឥឡូវគាត់ស្លាប់បាត់ហើយអ៊ំណេះ?

ខ៖ ចាំ!!

កះ គាត់ស្លាប់តាំងពីឆ្នាំណាវិញអ៊ំ?

ខះគាត់ស្លាប់២០១០។

កះ ២០១០ហេ?

ខះ ហ្នឹងហើយ។

កះ ស្លាប់ដោយសារមូលហេតុអីគេអ៊ំ?

ខះ គាត់ទឹកនោមផ្អែមដែរ!!ប្ដីញ៉ុមទឹកនោមផ្អែមតើ!!

កះគាត់អត់មានហូបអីណា ដូចជាជំងឺម៉ងអ៊ំហេ?

ខះ ការពិតគាត់ នៅជាមួយគាត់ហាំធ្វើបង្អែមគាត់មិនដែលនឹងហូបផង
គាត់អត់សូវចូលចិត្តបង្អែមផង ហើយតែគាត់កើតជំងឺហ្នឹង!!ឆ្ងល់ដែរ!!

កះដូចពេលខ្លះមួយហ្នឹងគឺជារោគមកម៉ងអ៊ំណេះ?

ខះ រោគម៉ងហ្នឹងហាំ!!

កះ ហើយឈឺបានប៉ុន្មានឆ្នាំទើបស្វាមីស្លាប់អ៊ំ?

ខះ គាត់កើតទឹកនោមផ្អែមហ្នឹងអាយុ៣៨ !!

កះហ្ហ៎!!

ខះអាយុ៣៨ហើយមកស្លាប់ស្លាប់អាយុ៥៣!

កះ ចាំអញ្ចឹង១០ឆ្នាំជាង!!១៥ឆ្នាំ!ឈឺ១៥ឆ្នាំអ៊ំ?

ខះចាំ!!

កះគាត់ទឹកនោមផ្អែម អញ្ចឹងបានគាត់ស្លាប់!! មានមុតមានដំបៅអីទេអ៊ំ?

ខះ មានដំបៅ កាត់ជើង!!

កៈអូ!!!

ខៈប្តីញុំមពេលកើតខ្លាំងមែនទែន ដំបៅហ្នឹងគាត់ជាដូចថាទៅពេទ្យសម្តេចឪហ្នឹង
ទៅពេទ្យសម្តេចហ្នឹង គេថតមើលជើងហ្នឹង
ដល់ពេលគេឃើញជើងហ្នឹងព្យាបាលអត់កើតវាដូចខូចឆ្អឹងខូចសរសៃអញ្ចឹងណាស់ពេទ្យគេ!!
ក៏គេសំរេចចិត្តកាត់ទៅ
គេក៏សួរយើងដែរថាសំរេចចិត្តកាត់ឬមួយក៏អត់?បើសិនកាលណាកាត់វារស់បានយូរ!!

កៈហ៊ឺ!!

ខៈ បើសិនជាអត់កាត់ទេ គាត់អត់យូរទេ!!គាត់និយាយអ៊ីចឹងណាស់ពេទ្យហាំ!!

កៈចាំ!!

ខៈថាអោយយើងគិតមើលទៅដេកគិតមើលទៅ
ដល់ហើយញុំមនឹងកូនអីហ្នឹងសំរេចចិត្តថាកាត់ទៅ អត់ធ្វើអីក៏អត់ទៅ នៅផ្ទះទៅណាស់!!

កៈចាំ!!

ខៈអោយបាននៅរស់អោយកូនឃើញមុខទៅ!!

កៈ ហ្នឹងហើយ!!

ខៈហើយសំរេចចិត្តថាកាត់ទៅ មិនបាច់ធ្វើអីទេ នៅតែផ្ទះទៅ!!

កៈហ៊ឺៗ!!

ខៈក៏កាត់ទៅ កាត់ទៅ កាត់ទៅបងដូចជាបាន៤ ៥ឆ្នាំដែរ!!

កៈ ហ្ហ៎អញ្ចឹងបានយូរដែរ!!

ខៈ ចាំរៀងបានយូរដែរ!!ហើយកាលហ្នឹងបើសិនជាអត់បានកាត់វិញ
ប្រហែលជាបានអត់ដល់មួយឆ្នាំទេ!!

កៈហ្ហ៎!!

ខ៖ហើយដល់ពេលហើយទៅកាត់ទៅបាន៩ ៥ឆ្នាំដែរ បានស្លាប់ហ្ន៎!!

ក៖ហ៊ី!!ដល់ពេលអញ្ចឹងទៅអ៊ំអើយញ៉ុមដូច
ពេលឈឺអញ្ចឹងយើងប្រៀបធៀនចិត្តយើងទៅចិត្តគាត់អញ្ចឹងវិញហាថាគាត់មិនដឹងពិបាកចិត្ត
ខ្លំាងប៉ុណ្ណាទេ!!ហើយអ៊ំជាប្រពន្ធហ្នឹង ក៏មិនស្រួលណាប៉ុន្មានដែរ!!

ខ៖ ហ្នឹងហើយមិនស្រួលទេ!!

ក៖ចា៎!!តែចេះគាត់បាន
ទោះគាត់ឈឺជំងឺហ្នឹងក៏គាត់នៅបានមើលអោយកូនឃើញ១៥ឆ្នាំដែរ!!ខ៖ចា៎!!

ក៖ពេលចាប់ផ្តើមឈឺជំងឺហ្នឹង!!អ៊ំពេលរៀបការជាមួយលោកពូហ្នឹង
ដូចរបៀបថាអើរគ្រាន់តែម្តាយឪពុកជាអ្នករៀបចំអោយឬក៏គ្រាន់តែស្រលាញ់គ្នាហើយរៀបការ
តែម្តង?

ខ៖ ម្តាយឪពុក!!

ក៖ ស្តីដណ្តឹងអោយ?

ខ៖ ចា៎!!ព្រោះអីប្តីញ៉ុមហ្នឹង ត្រូវជាសាច់ឈាមក្មួយម៉ែញ៉ុមដែរ!!!

ក៖ហ្ន៎!!

ខ៖ម្តាយគាត់ ម្តាយប្តីញ៉ុមហើយនឹងម៉ែញ៉ុមហ្នឹង បងប្អូនជីដូនមួយ!!

ក៖ហ្ន៎!!អញ្ចឹងជិតដែរ!!

ខ៖ ហើយចាស់ៗចេះតែផ្គូរផ្គងទៅណាស់  ប្តីញ៉ុមហ្នឹង ញ៉ុមអត់ដែលស្គាល់គាត់ទេ
ដោយសារម្តាយក្មេកញ៉ុមហ្នឹងគាត់មានប្តីទាហានហ្ន៎!!

ក៖ចា៎!!

ខ៖គាត់ទៅតាមប្តីគាត់ឆ្ងាយៗអញ្ចឹងទៅ!!គាត់ទៅនៅរតនៈគិរី
មណ្ឌលគិរីអីអញ្ចឹងទៅ!!គាត់ទៅតាមប្តីគាត់ទៅណាស់!!

ក៖ចាំ!!

ខ៖ហើយអញ្ចឹងគាត់អត់ដែលនៅស្រុកទេ!!ហើយអញ្ចឹងពួកញ៉ុមនៅណោះនៅកស្រុក
ហើយអញ្ចឹងកូនកូនហ្នឹងគ្មានដែលស្គាល់គ្នាទេ!!កាលជំនាន់អាពតបែកគ្នាគាត់ទៅនៅបាត់ដំប
ង
ទៅហើយដល់ពេលមកវិញអញ្ចឹងវិទៅម៉ែម៉ែជួបគ្នាអញ្ចឹងទៅមានកូនអីនឹងអាលផ្គូរផ្គងអីទៅចា
ស់ៗហាំ!!

ក៖ហ្នឹងហើយ សល់ពីសង្គ្រាមមកអញ្ចឹងទៅ!!!

ខ៖ សល់ពីសង្គ្រាមមក!!

ក៖ អោយតមានកូនពូជពង្សអីចឹងទៅ!!

ខ៖ ម៉ែក្មេកញ៉ុមអញ្ចឹងគាត់ហៅប្អូនគាត់ហាំ!!ជាហ្អែងមានកូនក្រមុំអីទេ
យើងភ្ជាប់សាច់ឈាមគ្នាវរវរឆ្ងាយ ដាច់ឆ្ងាយទៅណាស់
បងប្អូនលែងស្គាល់គ្នាកូនចៅអីណាស់!!

ក៖ចាំ!!

ខ៖គាត់ចង់ភ្ជាប់សាច់ឈាមមកបានបងប្អូនជួបគ្នាកុំអោយឆ្ងាយពីគ្នា!!

ក៖ចាំ!!

ខ៖ព្រោះអីបាត់គាត់ហ្នឹងចេះតែដើរចោលស្រុកឆ្ងាយៗអត់ដែលជួបម៉ែញ៉ុមអីវ៉ាន់អញ្ចឹង
ដល់ពេលគាត់ជួបគ្នានគាត់រលឹកគ្នាទៅណាស់!!

ក៖ចាំ!!

ខ៖ ដល់ពេលអញ្ចឹងទៅថាញ៉ុមមានតើ!!
ដល់ហើយអញ្ចឹងទៅគាត់ម៉ែក្មេកញ៉ុមហ្នឹងស្ដីញ៉ុមទៅ!!

ក៖ ហើយមានស្នេហ៍ចិត្តអំមុនទេមុនពេលហ្នឹងអីចឹងមុនពេលរៀបការ?

ខ៖ និយាយពីញ៉ុមវិញកាលមុនគាត់មកពីបាត់ដំបងហ្នំគេស្ដីមួយកំនរអត់យកទេ!!

ក៖ចាំ!!

ខ៖មិនយកទៅស្រាប់តែប្តីញ៉ុមហ្នឹងម៉ែញ៉ុម
យើងថាមិនយកហាំប៉ុន្តែម៉ែញ៉ុមថាមិនយកក៏ត្រូវតែយកដែរ
អញអោយទៅក្មួយអញហើយ!!ម៉ែហាំ សំរេចចិត្តថាអញ្ចឹងហើយ!!

ក៖ចាំ!!

ខ៖អឺចឹង!!

ក៖ អ៊ំក៏តាមអញ្ចឹងទៅ!!

ខ៖ ចាំ!!ញ៉ុមហ្នឹងក៏អញ្ចឹងទៅ!!

ក៖ អូយពិបាកណាស់អ៊ំ!!

ខ៖ ញ៉ុមគិតថានឹងជាគូរដែរហាំ ដូចថាប្រកែកមិនរួចហាំ!!

ក៖ ប្រកែកលែងឈ្នះហើយហោ?

ខ៖ ចាំប្រកែកលែងឈ្នះ!! គាត់ថាមិនបាច់ប្រកែកទេ!!

ក៖ចា!!

ខ៖ព្រោះអីអើរអញត្រូវតែលើកអោយហើយ!!លើកអោយទៅខាង!

ក៖ ហើយណោះក៏ព្រមតាមដែរ?

ខ៖ ប្តីញ៉ុមក៏គាត់ព្រមដែរ កាលគាត់មកភ្លាម ចុះកាល
ប្តីញ៉ុមកាលពីគាត់កំលោះគាត់ស្អាតដែរហ្នឹង!!

ក៖ ហ្នឹងហើយ!!

ខ៖ គាត់រកជួញ កាលហ្នឹងគាត់រកស៊ីនៅអូរ
កាលហ្នឹងគាត់រកជួញខោអាវខោប៊យហ្នឹង!!ក៖ហ្ហ៎!!ខ៖គាត់ជួញកង់ជួញអីទិញពីថៃហាំ!!គាត់មកលក់នៅផ្សារអូរ!!

កៈហ៊ីមិនធម្មតាដែរ!!

ខៈ គាត់មិនធម្មតាដែរហ្នឹង!!ដល់ម៉ែមកដល់ ម៉ែគាត់ផ្តូរផ្តងថាអញ្ចេក
អញស្តីកូនគេណោះហើយ ស្តីកូនគេបងប្អូនឯងហើយ!!

កៈ តែពេលហ្នឹងប្រាប់ឃើញមុខអ៊ំ អ្នកមីងនៅ?

ខៈ គាត់អត់ដែលឃើញទេ!!គាត់អត់ដែលមកស្រុកផងហ្នឹង!!

កៈហ្ហ៎!!

ខៈគាត់នៅរកស៊ីបាត់ដំបងហ្ហ៎!!បែកហើយហ្នឹងហាម៉ែគាត់មកមុនទៀតហាំ!!

កៈចាំ!!

ខៈ គាត់នៅរកស៊ីនៅបាត់ដំបង
នៅអូរណោះគេហៅជួញទិញឥវ៉ាន់ថៃយកមកលក់នៅអូរនោះ!!

កៈចាំ!!

ខៈផ្សារអូរហ្នឹងញ៉ុមអត់ដែលស្គាល់ទេ
ដល់ពេលគាត់មកស្រុកពួកម៉ាក់គាត់ប្រាប់អញ្ចឹងហើយគាត់មកលេងផ្ទះញ៉ុម
គាត់មកលេងទៅឃើញញ៉ុមឃើញអីទៅដូចគាត់អត់ប្រកែកដែរ!!

កៈ ចាប់ផ្តើម ស្រលាញ់ ចាប់ផ្តើមមានចិត្តហើយ!!

ខៈ ចាំ!!ដល់ហើយគាត់សន្សំលុយសន្សំអី កាលជំនាន់ហ្នឹង
ដល់ហើយម៉ែក្មេកញ៉ុមថាហេតុតែញ៉ុមហើយនឹងប្តីញ៉ុមជាគូរគ្នាហាំ!! គាត់លក់នំបញ្ចុកទេ
គាត់លក់នំបញ្ចុកយើងនៅផ្សារ
នៅស្តារចាស់នេះគាត់ទៅលក់នំបញ្ចុកនៅអាកន្លែងដើមពោធិ៍អើរមុខវត្តភ្នំហ្នឹងគេហៅ
កំពង់ផែអណ្តែតនោះ!!

កៈចាំ!!

ខះកំពង់ផែអណ្តែតហ្នឹង គាត់លក់សាច់គោអាំង គាត់លក់នំបញ្ចុកអីហ្នឹង កាលហ្នឹងដល់ពេលហើយទៅស្រាប់តែគាត់ថាតែមួយយប់ហ្នឹងគេកប៉ាល់ចូលមកគេហៅទិញប៊ិច !!

កះហ៊ុំៗ!!

ខះទិញប៊ិចហ្នឹងបានប៉ុន្មានកេសទេច្រើនដែរ មិនដឹងប៉ុន្មានទេ
ហើយគាត់ចំនេញបានលុយ១០០០!!

កះហ៊ីៗ!!

ខះ១០០០លុយខ្មែរយើងហ្នឹងទឹមតែចេញថ្មី យើងទឹមចេញហាំ ១០០០លុយខ្មែរហ្នឹង
គាត់បាន១០០០យប់ហ្នឹងគាត់យកមកអោយម៉ែញ៉ុមព្រលឹមឡើង
ហើយគាត់ថាអញ្ចេកណេះអញអត់ដឹងទេណាស់
ណេះអញជូនហ្អែង១០០០ការកូនទៅណាស់!!

កះពេលហ្នឹងច្រើនណាស់អ៊ំហេ១០០០?

ខះ ចាំ១០០០ហ្នឹងច្រើនណាស់!! ហ្អែងយកមកការកូនទៅណាស់!!

កះចាំ!!

ខះ អញរកមួយមិញបាន១០០០ណាស់ ហើយគាត់ប្រាប់ថាគាត់រកបានតែមួយយប់ហ្នឹងគត់ ស្អែកឡើងអត់ ខែក្រោយឡើងក៏អត់ដែរ ដូចថាកប៉ាល់ឡើងមកតែមួយជើងហ្នឹង
ចំអាត្រូវប៉ាន់ប៊ិចហ្នឹងម៉ងហាំ!!

កះចាំ!!ប្តីញ៉ុមលីប៊ិចមួយយប់ណាស់!!កះហ៊ី!!ខះលីប៊ិចយកមកលក់អោយម៉ូយនៅផ្សារហ្ញុំ!!

កះចាំ!!

ខះលីប៊ិចពីកប៉ាល់មកពួកទាហានហៅទិញ។

កះ ហ្នឹងហើយគួរព្រេងជួយពេលហ្នឹង!!

ខះ គាត់ប្រាប់ថារកបានតែមួយយប់ហ្នឹង ១០០០លុយខ្មែរកាលហ្នឹង ខ្លាំងរកប្រពន្ធបានមួយ
ម៉ែញ៉ុមការអត់អស់លុយទៀត!!

កៈ ម៉េចវិញអ៊ំ?

ខៈ កាលហ្នឹងហាំ !!ចាំការហ្នឹងសល់លុយ៧០០ទៀត!!

កៈហ្អ៎!!

ខៈពេលការញ៉ុមហើយហ្នឹងហាំ ម៉ែញ៉ុវេចលុយ
លុយចំនងដៃខាងម៉ែក្មេកញ៉ុមអីវ៉ាន់ហ្នឹងគាត់ហៅ
គាត់អត់យកចំនងដៃយកអីទៀតគាត់ហៅភ្ញៀវហៅអីអោយម៉ែញ៉ុមទៀត
ហើយលុយ១០០០ហ្នឹងគាត់ប្រគល់អោយម៉ែញ៉ុមអោយការញ៉ុមហើយប្តីញ៉ុមហ្នឹងទៅ។

កៈ ចាំស្រួលទៀត!!

ខៈ ចាំ ដល់ពេលហើយម៉ែញ៉ុមហ្នឹង
យកលុយមកការមកចាត់ចែងការហ្នឹងហើយមិនចំនងដៃខាងម៉ែក្មេកញ៉ុមហ្នឹងបាន៧០០ !!

កៈហ៊ឺៗ!!

ខៈ ៧០០ ម៉ែក្មេកញ៉ុមអត់មានសួររឿងចំនងដៃរឿងអីហ្នឹងទេ គាត់អត់ដែលការកូនផង!

កៈចាំ!!

ខៈ គាត់ការកូនដំបូងដែរដល់ពេលហើយទៅម៉ែវេចលុយទៅអោយ
ថាណោះបងលុយបងឯងហិ លុយចំនងដៃបងឯងអត់យកទេហេ ណោះនៅសល់៧០០ហិ!!
អាលុយបងឯងជូនញ៉ុម១០០០ហ្នឹង ញ៉ុមយកទៅចាត់ចែងការកូនហើយ
ហើយនេះលុយចំនងដៃខាងបងឯងហាំ!!

កៈចាំ!!

ខៈ អ៊ីចឹង!!ម៉ែក្មេកញ៉ុមហាំ អ៊ីចឹងអញនៅមានលុយ៧០០ទៀតអ៊ីចឹង ថាអ៊ីចឹងហិ!!
ជូនម៉ែញ៉ុម១០០០ហើយគាត់នៅសល់លុយ៧០០អញ្ចឹងអញអស់តែ៣០០ហ្នឹង
១០០នៅសល់៧០០ កាលហ្នឹងម៉ែញ៉ុមគាត់វេចបង្វិចលុយ
វេចបង្វិចទៅកាលហ្នឹងយើងលុយសុទ្ធតែលុយខ្មែរក្រដាសមួយកាក់ មួយកាក់ហ្នឹងក៏មានដែរ!!

ក៖ចាំ!!

ខ៖លុយខ្មែរយើងកាលហ្នឹងចាយមួយកាក់មួយកាក់នោះ!!

ក៖ចាំ!!

ខ៖មករិចមួយបង្វិចមកអញ្ចឹងហិ
លុយ៧០០យកទៅអោយម៉ែញ៉ុមម៉ែក្មេកញ៉ុមហ្នឹងយកទៅអោយដល់ផ្ទះទៀតម៉ែញ៉ុម
ម៉ែក្មេកញ៉ុមអត់មានសួររកទេ
គាត់អត់មានដឹងគាត់ថាគាត់អត់មានគិតគូររឿងចំនងដៃចំនងអីទេគាត់គ្រាន់តែដឹងថា១០០០
ហ្នឹងជូនទៅម៉ែញ៉ុមការម៉េចការទៅអីម៉េចអីទៅ ប៉ុន្តែគាត់ហៅភ្ញៀវ!!

ក៖ចាំ!!

ខ៖ហៅភ្ញៀវដល់គេចងដៃមកក៏គាត់អត់មានគិតគូរយកលុយចំនងដៃចំនងអីអត់ ជំនាន់ហ្នឹង។

ក៖ ហើយដល់ពេលអញ្ចឹងលុយ៧០០ហ្នឹងអោយទៅម្តាយរបស់អ្នកមីងទៀតទៅ?

ខ៖ គាត់
ម្តាយញ៉ុមជាអ្នកទុកដាក់លុយទាំងអស់ហ្នឹងដល់ហើយទៅម៉ែញ៉ុមរិចយកមកអោយម៉ែក្មេកញ៉ុ
ម។

ក៖ ហើយដល់ហើយទៅគាត់យកដែរអីចឹងទៅ?

ខ៖ យក ហើយដល់ហើយគាត់សរសើរថាអញ្ចេក
ហ៊ីហើយអញ្ចឹងអញនៅសល់នៅមានលុយ៧០០ទៀត!!

ក៖ ហេងហើយ!!

ខ៖ ហេអញអត់ដឹងទេនេះ
អញដឹងតែថាជូនឯង១០០០ហ្នឹងឯងយកធ្វើអីធ្វើទៅ!!ចំនងដៃអញបានប៉ុន្មានឯងយកទៅធ្វើអី
ទៀតយកទៅធ្វើអីទៅ!!

ក៖អីចឹងអំពេលការភ្លាមមកនៅជាមួយម៉ែឬក៏បែកផ្ទះភ្លាមមកនៅណោះមក?

ខ៖ ការហើយញ៉ុមមកនៅខាងផ្ទះម៉ែក្មេក!!

ក៖ហ្ហ៎!!

ខ៖ដោយសារម៉ែក្មេកញ៉ុមហ្នឹងគាត់នៅរកស៊ីនៅកន្លែងផែអណ្តែតហ្នឹងហា៎!!

ក៖ចា៎!!

ខ៖ដល់ពេលហើយទៅញ៉ុមនៅមើលប្អូនញ៉ុមហ្នឹងហា៎ ប្អូនថ្លៃពីរនាក់ប្អូនប្រុសៗហា៎!!

ក៖ចា៎!!

ខ៖ប្អូនហ្នឹងនៅរៀន ប្តីញ៉ុមក៏គាត់ទៅរកស៊ីនៅស្រុកជាមួយម៉ាក់ដែរអីចឹងហា៎!!

ក៖ចា៎!!

ខ៖ហើយអោយញ៉ុមហ្នឹងនៅផ្ទះ មើលប្អូនហ្នឹងទៅ ហើយរហូតដល់ពេលញ៉ុមមានទំងន់
កូនដំបូងហ្នឹងបានញ៉ុមបែកផ្ទះ!!

ក៖ចា៎!!

ខ៖បែកផ្ទះហ្នឹងបានញ៉ុមនៅខាងម៉ែញ៉ុមវិញ ទៅនៅខាង ហ្នឹងម៉ែក្មេកលែងនៅ
លែងនៅភ្នំពេញហើយហ្នឹងណាស់នៅផ្ទះដែរ!! ញ៉ុមធ្វើផ្ទះ មុនដំបូងញ៉ុមមកនៅផ្ទះម៉ែសិន
ហើយដល់នេះសន្សំលុយនៅជាមួយម៉ែក្មេក សន្សំលុយអត់បានទេ!!

ក៖ហ៊ីៗ!!

ខ៖ ដូចថាបងប្អូនច្រើនហូបជាមួយគ្នាអីចឹងណាស់!!

ក៖ចា៎!!

ខ៖សន្សំលុយ ពេលហ្នឹងប្តីញ៉ុមទៅដឹកដីដឹកអីលក់ ចំនេញបាន២០រៀល
២០រៀលអីអញ្ចឹងដែរ!! មិនមែន២០ដុល្លារទេណាស់!!២០រៀលលុយខ្មែរ!!

ក៖ ចា៎២០រៀលលុយខ្មែរ ពេលជំនាន់មុនថ្លៃ!!

ខ៖ ចាំហើយគ្រាន់តែយកមកទៅគ្រាន់តែមកដោះស្រាយគ្រួសារអត់បានលុយធ្វើផ្ទះទេ ហើយដីគេមានអោយអញ្ចឹងអោយតែយើងមានលុយធ្វើផ្ទះហាំ!!ហើយអត់!!

ក៖ចាំ!!

ខ៖ហើយដល់ពេលហើយម៉ែញុំមហៅថាអញ្ចេកមកនៅណេះជាមួយអញមក ហើយស៊ីបាយទៅ ស៊ីបាយអញទៅ!!ហើយរកលុយបានទុកទៅ ទុកសន្សំធ្វើផ្ទះនៅទៅ ព្រោះញុំមទំងន់ហើយហ្ហ៎!!

ក៖ចាំ!!!

ខ៖ដល់ពេលហើយមកនៅជាមួយម៉ែបានមួយឆ្នាំ បានសល់លុយធ្វើផ្ទះ!!

ក៖ហេ!!

ខ៖ សល់លុយប្ដីញុំមគាត់ទៅដឹកដីលក់អីចឹង ដូចញុំមនិយាយអីចឹង ២០រៀល ៣០រៀល !!

ក៖ ចេះតែសន្សំទៅ!!

ខ៖ សន្សំកាលហ្នឹងសល់ អត់មានចេះចាយអីផងហ្នឹង អត់ចេះចាយហើយនៅជាមួយម៉ែទៀតហើយម្ហូបអីម៉ែអ្នកដាំស្លរអោយហូបហ្នឹង ហើយយើងទិញអីបានមកលុយទុកហ្នឹងអីចឹងទៅ!!

ក៖ចាំ!!

ខ៖បានសន្សំលុយធ្វើផ្ទះ!!

ក៖ ចាំ!!ហើយអ៊ំពេលរៀបការ ដូចជារៀបការជាមួយស្វាមីហើយមកមានកូនប្រុសស្រីប៉ុន្មាននាក់ដែរ?

ខ៖ មានកូនប្រុសស្រី៦ប៉ុន្តែងាប់កូនស្រីមួយ!!

ក៖ អាយុប៉ុន្មាន?

ខ៖ ត្រូវស្រី៣ប្រុស៣!! កូនកើតមកទូចដែរហ្នឹងកូនង៉ែតហ្នឹង។

កះ ហ្វ៎!!អ៊ីចឹងទឹមតែកើតបានមួយខែឬក៏ទឹមតែកើតភ្លាមៗអ៊ំ?

ខះ ទឹមតែកើតភ្លាម។

កះ ហ្វ៎អ៊ីចឹងអត់ទាន់មានដាក់ឈ្មោះដាក់អីអោយគ្នាផងហ្នឹងអ៊ីចឹង?

ខះ អត់ទាន់បានដាក់ឈ្មោះអោយផង។

កះ ចាំអ៊ីចឹងអ៊ំ៥នាក់ទៀត
ពួកគាត់ឈ្មោះអីគេខ្លះអ៊ំអាចរៀបរាប់តាំងពីបងគេរហូតដល់ពៅគេទាំងត្រកូលរបស់គាត់ហាំ??

ខះ ទី១ មករា ។

កះចាំ!!

ខះហើយទី២ឈ្មោះអាម៉ាប់ ហើយទីបីឈ្មោះចាន់នូ ទីបួនប្រុសឈ្មោះចាន់ណា ។

កះចាំ!!

ខះទីប្រាំឈ្មោះអាញាញ់ពៅគេ!!

កះ ចាំ!!អញ្ចឹងមិញភ្លាចមើលថ្ងៃខែឆ្នាំកំណើតរបស់ស្វាមីអ៊ំអ៊ីចឹងស្វាមីអ៊ំគាត់កើតនៅក្នុងថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៦០ នៅភូមិកោះគរ ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល ប្រទេសកម្ពុជា តែមិនមែនទេអ៊ំ
មិនមែនស្រុកកំណើតគាត់ទេហេ??តែគ្រាន់តែគាត់មកផ្លាស់ទីមកនៅណេះទេហី?

ខះ ប្តីញ៉ុមហេ?

កះចាំអ្នកស្រុកកំណើតមកពីណាវិញ?

ខះ អើរប្តីញ៉ុមស្រុកកំណើតម្តាយគាត់នៅហ្នឹងដែរនៅជាមួយគ្នា!!

កះ ហ្វ៎អ៊ីចឹងពេលគាត់កើតកើតនៅហ្នឹងដែរទេហេ?

ខ៖ គ្រាន់តែពេលគាត់កើតមិនដឹងគាត់កើត ព្រោះគាត់ដើរទៅតាមប្ដីរហូត(ព្រោះប៉ាគាត់ជាទាហានម្ដាយត្រូវទៅជាមួយរហូត)មិនដឹងគាត់កើតនៅស្អីក៏មិនដឹង គាត់ធ្លាប់នៅបឹងទំពន់ដែរហាកាលហ្នឹងហាំ!!

ក៖ហ្ហ៎!!

ខ៖សង្ស័យកើតនៅភ្នំពេញហើយប្ដីញ៉ុម ។

ក៖ ហ្នឹងហើយ អ៊ិចឹងអ៊ំកូនទាំងអស់របស់អ៊ំដូចជាគាត់អាយុច្រើនៗបានលោកពូស្លាប់អ៊ីចឹងណោះ?ព្រោះគាត់ទឹមតែស្លាប់២០១០នេះហ្នឹង!!

ខ៖ មើល ទឹមតែការបានកូន២។

ក៖ ចាំតែឥឡូវការអស់នៅ?

ខ៖ តែឥឡូវការអស់ហើយនៅកូនពៅមួយនៅប្រុស!!

ក៖ ទឹមការកូនពៅមួយទេហេ អាយុប៉ុន្មានកូនពៅ?

ខ៖ អាហ្នឹងវាទំនើបពេក អាយុ២៦ហើយនេះ។

ក៖ ពៅគេ២៦ហើយ?

ខ៖ ចាំ!!

ក៖ ប្អូនញ៉ុមមួយឆ្នាំ។

ខ៖ ឆ្នាំរកា!!

ក៖ ហ្នឹងហើយប្អូនញ៉ុមឡើង២ ៣ឆ្នាំហ្ហ៎!!ហ៊ីបើគិតតាមឆ្នាំខ្មែរញ៉ុមអាយុ២៩ហើយណាស់អ៊ំ តែបើរាប់តាមឆ្នាំបារាំងញ៉ុមទឹមតែ២៧ទេ!!ឆ្នាំខ្មែរយើងលើស២ឆ្នាំរហូតហ្នឹង!!

ខ៖ចាំ!!

ក៖អ៊ីចឹងអាអូនបើនេះទឹមតែ២៤អ៊ីវ៉ាន់ហ្នឹង!!ចាំ!!

ខ៖ កើតឆ្នាំរកា!!

ក៖ ទំនើបម៉េចមីង?

ខ៖ ទំនើបអត់ទាន់ចេះរកស៊ីអីផងហ្នឹង
ទៅរកប្រពន្ធអោយម៉េចខ្លាចរកស៊ីចិញ្ចឹមគេអត់រស់!!អញ្ចឹងអោយនៅចាស់បន្តិចទៅ!!

ក៖ ឥឡូវនៅរៀនតើហី?

ខ៖ មានរៀនឯណា!!ធ្វើការធ្វើមិនបាន ធ្វើខាងអញ្ចឹងហា!!

ក៖ ហ្ហ៎ខាងម្ខាងសិលាហ្នឹងហី?

ខ៖ ចាំហ្នឹងហើយគេធ្វើតាមអីចឹង!!

ក៖ ជាមួយមីងយៀបហីអី?

ខ៖ ប្តីយៀបក៏ធ្វើអញ្ចឹងដែរ!!

ក៖ ហ្នឹងធ្វើជាមួយហ្នឹងហោ?

ខ៖ ហ្នឹងហើយ!!ជូនវាធ្វើជាមួយជូនវាធ្វើជាមួយក្មួយញ៉ុមមួយទៀត!!

ក៖ហ្ហ៎!!ចាំ!!

ខ៖
ព្រោះគ្រូសារខាងក្មួយញ៉ុមគេសុទ្ធតែចេះខាងអាអញ្ចឹងហា!!អញ្ចឹងអាណាមានការងារធ្វើចេះតែហៅទៅធ្វើទៅ!!

ក៖ចាំ!!

ខ៖តិចអានេះហៅតិចអានោះហៅ
ណាស់តែវាខ្ជិលអត់ទៅធ្វើហ្នឹង!!ហៅច្រើនពេកស្រេចតែវាអត់ទៅធ្វើហ្នឹង
ត្រូវចិត្តបានទៅស្រេចតែមិនត្រូវចិត្តស្រេចតែមិនធ្វើ។

ក៖ ហ្នឹងដោយសារអត់មានបន្ទុកតែមានបន្ទុកខំហើយ។

ខ៖ចាំ!!

ក៖អ៊ិចឹងប៉ុន្មានឆ្នាំទៀតរកប្រពន្ធអោយ ឥឡូវអោយខំប្រឹងបន្តិច!!

ខ៖ចាំ!!

ក៖ អ៊ិចឹងអ្នកមីងកូនទាំងអស់សុទ្ធតែបានទៅរៀនទាំងអស់ណាអ្នកមីងហោ?

ខ៖ កូនរៀបបានគ្រប់ៗគ្នាប៉ុន្តែមិនបានរៀនខ្ពស់ទេ!!

ក៖ចាំ!!

ខ៖ អាខ្លះរៀនបានត្រឹមថ្នាក់ទី៧ហ្នឹងឈប់ហើយ!!

ក៖ ចាំអ៊ិចឹងអ្នកមីងស្វាមីអ្នកមីងគាត់ជាអ្នកធ្វើចំការជាមួយអ្នកមីងដែរអ៊ីចឹងទៅហី?

ខ៖ ពីដើមមកធ្វើចំការជាមួយគ្នា ដល់លើកក្រោយមកគាត់អត់
ដល់ពេលអាយុ៣៨គាត់ទៅធ្វើប៉ូលីសទៅ។

ក៖ហ្ហ៎!!

ខ៖ នេះរូបថតនេះ!!

ក៖ ហ្នឹងរូបថតពេលអាយុ៣៨ហ្នឹងហោ?

ខ៖ ហ្នឹងហើយ៣៨ ពេលគាត់ចូលធ្វើប៉ូលីសដំបូងហ្នឹងហ៊ា!!

ក៖ចាំ!!

ខ៖ហ្នឹងហើយរូបថតហ្នឹងហើយចូលដំបូងកាលហ្នឹង ។

ក៖ តែដល់ពេលស្លាប់អីអញ្ចឹងទៅដូចគេមានអោយអីៗដូចជាងារប៉ូលីសអីអញ្ចឹងទៅណាំ?

ខ៖ អោយ!! ដូចគេបើកប្រាក់ខែផ្តាច់អោយណាស់ ។

ក៖ចាំ!!

ខៈគេបើកប្រាក់ខែអោយគាត់ច្រើនដែរហ្នឹង!!អាប្រាក់ខែ៩លានហ្នឹងផ្សេង
ហើយអាប្រាក់ខែនោះគេអោយប៉ុន្មាន ៥ខែគុណទៅប្រាក់ខែបាន៣លានអីដែរ។

កៈចាំ!!

ខៈ ប្រាក់ខែគេអោយ!!

កៈអ៊ិចឹងបានច្រើនដែរ!!

ខៈ លុយអាគេអោយនោះបូជាសពនោះ១លានជាងទៀត គេបើកផ្តាច់អោយហាំ!!

កៈចាំ!!

ខៈហើយឥឡូវហ្នឹងប្រាក់ខែខាងសង្គមកិច្ចហ្នឹងពីរនាក់ញ៉ុមហ្នឹង៥០០០ ១០០០០ៗ
គ្រាន់ញ៉ុមបើកមួយឆ្នាំអីមកនៅធនាគារអេ ស៊ី លីដាហាំ!!

កៈហ្ហ៎!!មានអីចឹងទៀត!!

ខៈជួនកាលមួយឆ្នាំអីញ៉ុមទៅបើកហើយមួយឆ្នាំអី ១៨០០០០អីអីចឹង!!

កៈ ចាំហ្នឹងហើយ!!ចាំ!!
អ៊ិចឹងអ្នកមីងសំរាប់ចូលដល់ជីវតអ្នកមីងចូលដល់របបសង្គ្រាមហាំពេលនៅក្នុងប៉ុល ពត
ហាអត់ទាន់ដល់ប៉ុល ពតទេ មីងនៅក្នុងលន់ នល់ សិន លន់ នល់នៅហ្នឹងទេអីចឹងណោះ?

ខៈ នៅអើរជំនាន់លន់ នល់ ឆ្នាំ!!

កៈ ឆ្នាំ៧០ដល់៧៥(១៩៧០ ១៩៧៥)។

ខៈ ឆ្នាំ៧០(១៩៧០) មុនឆ្នាំ៧០(១៩៧០)អីហ្នឹងញ៉ុមនៅស្រុកហ្នឹង
នៅស្រុកឈ្យូងលៀបហ្នឹងហាំ!!

កៈចាំ!!

ខៈ ដល់ពេលឆ្នាំ៧១ ៧២(១៩៧១ ១៩៧២)
គេជំលៀសទៅនៅកោះខែលទៅនៅខាងក្រោម!!កៈហ៊ើ!!

ខះដល់ពេលឆ្នាំ៧៥(១៩៧៥)ហ្នឹងគេអោយឡើងមកលើវិញ។

កះ មឹងពេលក្នុងលន់ នល់ ហ្នឹងមានឮអីទុងតាំងអីច្រើនទេ គ្រាប់បែកគ្រាប់អីផ្លោងហាំ??

ខះ ដេកតែក្នុងត្រង់សេហ្នឹងញ៉ុម!!

កះ មើលមឹងមើលនិយាយអោយអស់មើល ថាវាលំបាកវេទនាម៉េចខ្លះទៅ?

ខះ មើលកំពុងតែលេងៗអិចឹងហិស្រាប់តែអាស្លាបកាត់គេវើៗៗៗងើៗៗៗ
ដូចគេដូចយើងដូចមាន់អញ្ចឹងដែលឮសូរខ្លែងស្រាក់រុញចូល!!

កះ រត់ចូលរកម៉ែ!!

ខះ
រត់ចូលរកម៉ែអញ្ចឹង!!លេងៗកំពុងតែលេងៗអិចឹងលឺសូរសំលេងអាស្លាបកាត់អាហ្នឹងវាមកទំលាក់គ្រាប់ហើយ អាស្លាបកាត់ហ្នឹង អញ្ចឹងទេវាហោះក្រឡឹង វាត្រូវឃើញអីវាបាញ់ៗ
ហើយត្រូវអីអើរពេលឃើញវារត់ចូលពួនរត់ចោលត្រង់សេអីអស់ហើយ!!

កះចាំ!!

ខះដល់ហើយតែអាស្លាបកាត់ហ្នឹងមកពីថ្ងៃយប់ឡើងដឹងតែអាបេមកចាក់ហើយ!!
អារណ្ដៅអាបេប៉ុនណាណើ!! បើចំហើយខ្ទេចអស់ហើយរកសាកសពអីអត់ឃើញទេ!!

កះ ជំរៅទៅប៉ុន្មានទៅអ្នកមឹងរណ្ដៅអាបេហ្នឹង?

ខះ ជ្រៅជំរៅយើងដូចយើងជីកស្រះអញ្ចឹងណាស់!!

កះ វាគ្មានអោយសល់អីទេ!!

ខះហ្នឹងហើយវាគ្មានអោយសល់អីទេ រណ្ដៅវាប៉ុនផ្ទះយើងហ្នឹងហាំ!!!

កះចំ!!

ខះរណ្ដៅអាបេហ្នឹងហាំ!!

កះចាំ!!

ខះតែអាស្លាបកាត់មកក្រឡឹងពីថ្ងៃហើយដឹងតែពេលយប់អាបេមកចាក់ហើយ !!

កះ អិចឹងដឹងខ្លួនរត់អោយហើយ?

ខះ ដឹងខ្លួនរត់ទៅ!!ងាប់មួយកំនរគ្នាហ្នឹង បើពេលអាបេមកចាក់ហ្នឹងហាំ!!!

កះហ៊ឺ!!!

ខះ កាលពីជំនាន់ហ្នឹងម៉ែញ៉ុមគាត់ជីកត្រង់សេអោយកូននៅក្នុងត្រង់សេហ្នឹង ម៉ែញ៉ុមគាត់ដាក់គ្រែនៅក្នុងត្រង់សេហ្នឹងទៅចងមុងអោយដេកនៅក្នុងដីហ្នឹងហាំ!!

កះ ចាំ!!តែគ្រាន់តែធ្វើជំបូលធ្វើអីអញ្ចឹងទៅហី?

ខះ ធ្វើជំបូល!!

កះ ដូចរបៀបថាដាក់ប៉ាងសីមកដាក់ដីពីលើហើយដាក់ស្លឹកឈើដាក់អីទៅអ្នកមីងហេ?

ខះ អត់ទេ ត្រង់សេខ្លះគេមានធ្វើគំរបដាក់ឈើធំៗគ្របពីលើដើម្បីការពារគ្រាប់ហាំ!!

កះហ្ហ៎!!

ខះការពារគ្រាប់ការពារពេលបាញ់អីអញ្ចឹងទៅវាមាន មានអាឈើយើងធំៗហ្នឹងធ្វើគំរបហាំ!!

កះហ៊ឺៗ!!

ខះការពារកុំអោយត្រូវកូនដេកក្នុងនៅទៅ!!

កះចាំ!!

ខះអាស្លាបកាត់ហ្នឹងមកចូលក្នុងត្រង់សេហ្នឹងទៅ ហើយពេលយប់អញ្ចឹងគាត់ពិបាកអី យប់កូនច្រើនគាត់ពិបាកអី កូនដេកពេញកន្ទេលអីស្លាបកាត់មកអញ្ចឹងទៅ រត់ចូលតែម៉ែកូននៅលើគោក!!

កះហ៊ឺ!!

ខះ ម្លោះហើយជីករណ្តៅដាក់គ្រែអោយកូនទៅ គ្រែហ្នឹងអត់មានជើងទេណាស់!!

ក៖ចាំ!!

ខ៖គ្រែធ្វើលាតទេ ដាក់កូនក្នុងហ្នឹង
អោយកូនចងមុងដេកនៅក្នុងហ្នឹងទៅ!!បើចំមិនដឹងធ្វើម៉េចទេ ងាប់ទៅ!!

ក៖ដូចជាបើជាដូចអាយុបានតែប៉ុណ្ណឹង!!

ខ៖ ហ្នឹងហើយ ខ្វះអីអ្នកចាំផ្ទះ ខ្លះចំស្លាប់អស់មួយផ្ទះក៏មាន!!

ក៖អូយ!!

ខ៖យាយញ៉ុមចំរណ្ដៅអាបេមកចាក់យប់ហ្នឹង រណ្ដៅអាបេមកចំផ្ទះហើយហ្នឹង!!

ក៖ ហ្នឹងហើយ អូយអញ្ចឹងពិបាកណាស់អ៊ំ !! អ៊ំដល់ពេលអញ្ចឹងធ្លាក់ត្រូវផ្ទះអ្នកណាគេមួយ
ព្រឹកឡើងទៅមើលសាកសពអីវ៉ាន់ពេញហ្នឹងហើយហេ?

ខ៖ ទៅមើលសាកសពខ្លះក៏ឃើញទៅ ខ្លះក៏ខ្ទេចញ៉ុងអស់ទៅ ខ្លះក៏មិនដឹងទៅខាងណាទៅ
បើរណ្ដៅអាបេឡើងលិចក្បាលបាត់ណោះ!!

ក៖ ចំ!! ម៉ត់ម៉ងអ៊ំដល់ដាក់ទៅ?

ខ៖ ម៉ត់ម៉ង ដាក់ចំដឹងតែខ្ទេចហើយ រកសាកសពអត់ឃើញទេ!!

ក៖ហ៊ឺៗ!!

ខ៖ បើត្រូវអំបែង ខ្លះវិញដូចខ្លះថា វាចាក់អញ្ចឹងវាខុសអីអញ្ចឹងទៅណាស់ ៤
១០ម៉ែត្រពីផ្ទះវាខ្ទៀតអំបែងហាំ!!

ក៖ហ៊ឺៗ!!

ខ៖អំបែងវាប៉ុនៗបាត់ដៃហ្នំអាបេហាំ!!

ក៖ចាំ!!

ខ៖ខ្ទៀតអំបែងទៅត្រូវយើង ខ្លះក៏ត្រូវទៅងាប់ទៅខ្លះក៏របួសទៅណាស់!!

កៈហ៊ឺៗ!!ហើយមីងទំលាក់ម្តងប៉ុន្មានគ្រាប់ទៅអាបេហ្នឹង?

ខៈ ជួនកាលមួយគ្រាប់ជួនកាលម៉ាដឹកមក២ ៣គ្រាប់អីអញ្ចឹងទៅ!!

កៈហ៊ឺ!

ខៈតែវាដឹកមកហើយវាទំលាក់ចោលហើយ វាអត់ដឹកយកទៅវិញទេ!!

កៈ ហ៊ឺសំបូរលុយធ្វើ ទំលាក់គ្រាប់ហ្នឹងទៀតណាស់!!និយាយទៅសង្គ្រាមអិចឹងម៉ង!!

ខៈ និយាយទៅរណ្តៅអាបេនៅនេះ
ទឹមតែគេលុបគេលុបបាត់ហា!!លុបដីលុបអីចាក់ទៅណាស់!!

កៈចាំ!!

ខៈបើកាលយើងនេះយើងមានអ្នកណាគេលុបយើងបែកហើយហ្នឹង
រណ្តៅអាបេធ្វើស្រូវធ្វើអីឃើញតែរណ្តៅអាបេហ្នឹង!!

កៈមានអាណាខ្លះអត់ទាន់ផ្ទុះអីវ៉ាន់អត់អ្នកមីង?

ខៈ ដូចអត់មានឃើញអាណាអត់ទាន់ផ្ទុះផង។

កៈ ទំលាក់ហើយដឹងៗៗអញ្ចឹងម៉ង?

ខៈដឹងៗអីចឹងទៅ ញ៉ុមឃើញផ្ទុះតែអញ្ចឹងរហូត!!

កៈ ចាំអីចឹងអ្នកមីងពេលដល់ពេលបែកពីលន់ នល់ ហ្នឹងមានអារម្មណ៍ថាចូលដល់ប៉ុល
ពតវិញគិតថា ដូចគិតថាចប់សង្គ្រាមមានអារម្មណ៍សប្បាយចិត្តអីទេ តែអត់ដឹងថាមានប៉ុល
ពតទៀតហ្ន៎??

ខៈ ពេលយើងនៅសង្គ្រាមយើងនៅរត់លូតរហូតយើងខ្លាចគ្រាប់ហាំ
តិចទៅយើងឮកាំភ្លើងបាញ់គ្នាពព្រឹពព្រុសរហូត ធ្វើចំការធ្វើធ្វើអីចឹងទៅនៅតែភ័យ
លឺតែបាញ់ហ្នឹងលឺបាញ់ម្តុំៗហ្នឹង ហើយញ៉ុមធ្វើការដូចយើងនៅព្រៃកចីហ្នឹងអញ្ចឹង!!

កៈចាំ!!

ខះហើយទាហានអីវានៅម៉្តុំខាងហ្នឹង ហើយបាញ់គ្នាអញ្ចឹងទៅពព្រុសពព្រាស់ យើងធ្វើចំការចេះតែធ្វើទៅបើមិនធ្វើបានអីហូប!

កះចាំ!!

ខះហើយអិចឹងភ័យចេះតែភ័យខ្លាចចេះតែខ្លាច ធ្វើនៅតែធ្វើនៅតែធ្វើហ្នឹង!! ហ្នឹងអាហ្នឹងជំនាន់នៅសង្គ្រាមហាំ!!

កះហ៊ីៗ!!

ខះដល់ពេលយើងបែកសង្គ្រាមហើយទៅយើងជំនាន់អាពតហ្នឹងអត់ភ័យរត់លូនទេ តែធ្វើការទាំងយប់ទាំងថ្ងៃ!! រែកដី!!

កះចាំ!!

ខះអ្នកណាអីខុសអីតិចតួចគេយកបាញ់ចោលហើយ!!

កះ តែខុសអីបន្តិចបន្តួចហ្នឹងគឺថា!!

ខះយកវ៉ៃចោលកោះគរហ្នុំ!!ដឹកទាំងខ្សែទៅ!!

កះ ព្យល្បីណាស់កោះគរហ្នឹង!!!គេសម្លាប់មនុស្ស!!គេត្រូវឆ្លងទូកទៅម្ខាងទៀតមែនអ៊ំ?

ខះ ឆ្លងទូក!!

កះ អ្នកមីងដល់ពេលចូលដល់សង្គ្រាមមកអ៊ីចឹងមានអារម្មណ៍ម៉េចដែរ ដល់ពេលអត់មានអីហូបឬក៏ថាប្រឈមមុខថានឹងមិនដឹងថាគេយកទៅអង្គាល់ម៉េចដែរអារម្មណ៍?

ខះ ភ័យខ្លាចរហូត!!គេប្រើធ្វើអីក៏ធ្វើដែរ !!

កះចាំ!!

ខះព្រោះថាខ្លាចឃើញអ្នកដែលខុសអ្នកដែលរអ៊ូរទាំអីអញ្ចឹងឃើញខុសគេយកទៅហាំ!!អញ្ចឹង អាអ្នកនៅហ្នឹងហាមិនដឹងខ្លួនឯងថាថ្ងៃណាគេយកទៅដែរទេ!!

ក៖ហ៊ឺៗ!!

ខ៖អ៊ីចឹងចេះតែខំហើយ
គេអោយចុះទឹកអាដេញខែកក្តិកហាំបងរងាអើយរងាគេអោយចុះបោចស្មៅទឹកត្រឹមករហាំ!!ក៏
ទៅដែរអត់មានហ៊ានប្រកែកទេខ្លាចព្រោះខ្លាចគេយកវៃចោលហ្ហ៎!!

ក៖ពេលចុះទៅធ្វើការងារហ្នឹង មានគេចុះមើលគេតាមដានអីគេទៀតអ្នកមីងហោ?

ខ៖ ប្រធានក្រុមគេដើរតាមជាមួយយើងតែរហូតហ្នឹង!!

ក៖ហើយចាំវាយការណ៍?

ខ៖ ហ្នឹងហើយតែយើងធ្វើអីខុសគេវាយការណ៍ហើយ!!

ក៖ ហ៊ឺតែមើលអ៊ីចឹងទៅណោះមីងណោះ?

ខ៖ ហ្ហ៎បើថាអ្នកហ្នឹងខ្ជិលណាស់ខ្ជិលធ្វើការធ្វើអីអញ្ចឹងអត់យូរទេ
ដូចថាគេហៅទៅកន្លែងកងពិសេសហើយ!!
ថាកងពិសេសហ្នឹងគឺសំរាប់តែគេបញ្ជូនទៅហើយ!!

ក៖ចាំៗ!!

ខ៖ តែបើយើងកងអត់ពិសេសហ្នឹង គេប្រើអីយើងចេះតែធ្វើទៅ!!

(មិត្តភក្តិ)៖ តែមិនមែនអាក្រក់តែទាំងអស់គ្នាទេគន្ធា!!
អ្នកខ្លះក៏មានអ្នកចិត្តល្អខ្លះដែរប្រលេងអីជាមួយយើងអ៊ិចឹងដែរ!!

ខ៖ លេងសើចអីធម្មតាហ្នឹង តែគ្រាន់តែយើងហត់នឿយហើយហូបអត់ឆ្អែត!!ញ៉ុមហាំបង
បើនៅជំនាន់អាពតញ៉ុមធ្លាប់អស់ហើយទៅធ្វើការបោចស្មៅទឹកត្រឹមករហ្នឹងឡើងមកវិញហាំ!!
គេដាក់បបរមួយកូនឆ្នាំងប៉ុណ្ណឹងគ្នា១០នាក់ហាំ!!
ហើយស្មានតែគេអោយអស់ប៉ុណ្ណឹងគេថែមអោយទៀតបងឯងមើល!!
ទៅទៅបោចស្មៅនៅស្អាងស្រាប់តែគេយកបបរមួយឆ្នាំងប៉ុណ្ណឹងមកញ៉ុមបានតែមួយកូនវែក
ស្មានតែអស់ទៅគេថែមអោយមួយឆ្នាំងអីទៀតអត់
បានតែប៉ុណ្ណឹង!!មួយកូនវែកហ្នឹងទៅ!!មួយថ្ងៃវាស់ល្ងាចហ្នឹងទៅធ្វើការ។

ក៖ ហើយដល់ពេលអ៊ីចឹងមានកំលាំងឯណាធ្វើបើអត់មានអីហូបហ៎ា??

ខ៖ ហើយចេះតែទៅហើយត្រុយៗៗៗទៅហើយ!!

ក៖ចុះដល់ពេលឃើញអីហូបបានចេះតែលួចហូបអញ្ចឹងទៅអ្នកមីងហោ?

ខ៖ មានអីលួចហូបបើរបស់គាត់ដឹកយកមកអោយហ្នឹងយើងធ្វើវការអ៊ិចឹងគេបររទេះដឹកបបរទាំងធុងដូចដាក់ធុងអញ្ចឹងណាស់!!!ហើយគេដួសវាល់ចែកគ្នាទៅ!!ជូនកាលគេចែកពោតម្នាក់២ ជូនកាលចេកម្នាក់៥!!

ក៖ចា៎!!

ខ៖អត់បាយតែញឹកហ្នឹងញ៉ុម!!

ក៖ ហើយចុះដល់ពេលមុនហ្ហ៎អ្នកមីង
តែដល់ពេលមកដល់ផ្ទះវិញមានអីហូបទេហី?យាយអីវ៉ាន់ផ្តល់អោយហោ ឮស្តាប់ពេលមុនហ្ហ៎?

ខ៖
យាយកាលពេលជំនាន់អាពតយាយមានហូបប៉ុន្តែយាយនៅខាងសិត្សទេណាស់ហើយប៉ុន្តែញ៉ុមនៅខាងអង្គភាពណោះ!!

ក៖អ៊ីចឹងអត់បានមកណោះផង?

ខ៖អត់កមានបានជួបគ្នាទេ យាយនៅដោយយាយថៅនៅដោយថៅទេ!!

ក៖សុំគេមកនៅជាមួយអត់បានទេហី?

ខ៖ អត់បានទេ!!

(មិត្តភក្តិ)៖ គេយកយើងបញ្ជូនទៅកងចល័តអីអញ្ចឹងទៅ!!

ខ៖ អ់តមានកូនក្មេងអីនៅជាមួយ តែកូនក្មេងអញ្ចេះក៏ទៅកន្លែងមើលក្មេងដែរ
កន្លែងកុមារដែរ។

ក៖ចា៎!!

ខ៖ហើយយើងអង្គភាពណោះល្វាចឡើងដេញគេមានអីអោយស៊ីស៊ីទៅពេលហ្នឹងទៅ!!

ក៖អញ្ចឹងអ្នកមីងពេលហ្នឹងកំពុងតែពេញរូបពេញរាងហើយហោ?

ខ៖ អាយុ អាយុ១២ ១៣ទេ!!

ក៖ ហ្អ៎អាយុទឹមតែ១២
១៣ទេ!!ហោមីងកើត៦២(១៩៦២)អ៊ីចឹងមកដល់៧២(១៩៧២)មីង១០ដល់៧៥(១៩៧៥)អើរ១៣
១៣មែន!!ហ្នឹងហើយ!!ទឹមតែប៉ុណ្ណឹង!!

ខ៖ ១៣!! ដល់ពេលបែកអាពតហើយអាយុទឹមតែ១៦!!

ក៖ ហ្អ៎អញ្ចឹងការអាយុ១៦ឆ្នាំ?

ខ៖ អាយុ១៧!!

ក៖១៧!!

ខ៖ ចុះយើងបែកអាពតហើយភ្លាមយើងអាយុ១៦បង!!ការអាយុ១៧ហ្នឹង បែកអាពតហើយ!!

ក៖ចំឃ្យូរដែរហើយហ្នឹងការ!!

(មិត្តភក្តិ)៖ ពេលបែកមកហើយញ៉ុមការអាយុ២១ប្តី២៣។

ក៖ហ៊ីម៉ែបង!! អ្នកមីងជួរចត់ខ្លាំងជាងគេនៅក្នុងប៉ុល ពតហ្នឹងអីគេវិញទៅ?

ខ៖ និយាយទៅ អាមួយជួរចត់រឿងរត់គ្រាប់ !!

ក៖ អាហ្នឹងលន់ នល់!!

ខ៖ចា៎!!លន់ នល់ យើងវ៉ៃគ្នាជាមួយលន់ នល់ ទាហាន !!

ក៖ខ្មែរក្រហម!!

ខ៖ ខ្មែរក្រហមហើយលន់ នល់ វ៉ៃគ្នា!!យើងញ៉ុមនៅទូចៗដែរ
ដូចញ៉ុមនិយាយថាយើងដេកនៅក្នុងតែត្រង់សេហ្នឹងអ៊ិចឹងណាស់!!

ក៖ចាំ!!

ខ៖នៅអាយុ១០ហើយដល់យើងបែកឆ្នាំ៧៥(១៩៧៥)យើងអាយុ១៣ឆ្នាំហ្នឹង!! ១៣ ១៤ ១៥ ១៦ហ្នឹងបែកមកវិញទៅណាស់!!

ក៖ហ៊ឺៗ!!

ខ៖បែកមកវិញ១៦ អត់បានចូលរៀននឹងគេវិញទេ!!គេស្ដីតាំងពី១៦ហ្នឹងណោះ!!មានបានរៀននៅសាលាហ្នឹងវិញណា បានមកការហើយ១៧ហ្នឹង ការហើយបានមករៀនអក្ខរកម្មហ្នឹង !!

ក៖ចាំ!!

ខ៖រៀនហើយអក្ខរកម្មហ្នឹង១៨កូនមួយ កូនហ្នឹងក៏ស្លាប់ទៅ កូនដំបូងហាំ!!

ក៖ចាំ!!

ខ៖១៩កើតអាហ្នឹងមួយទៀតនេះកើតអាមិញនេះ កើតអាឆ្នាំចនេះ!!

ក៖ ចាំអញ្ចឹងអ្នកមីងពេលហ្នឹងដូចមានដែលធ្លាប់ឃើញមានអ្នកណាសំលាប់មនុស្សចោលក្នុងពេលប៉ុល ពត?

ខ៖ ញ៉ុមអត់ដែលឃើញគេសម្លាប់ទេ !!!ព្រោះគេយកទៅសម្លាប់ហ្នឹងគេយកទៅសម្លាប់នៅកោះគរណោះទេ!!

ក៖ចាំ!!

ខ៖គេអត់អោយយើងឃើញទេ តែខុសអីក៏គេយកទៅកោះគរដែរ។

ក៖ចាំ!!

ខ៖ភាគច្រើនគេអ្នកយកទៅកោះគរភាគច្រើនគេអ្នកពួក១៧ !!

ក៖ អ្នកថ្មីហោ?

ខះ អ្នកថ្មីបែកយកពីភ្នំពេញទៅហាំ!

កះចាំ!!

ខះហ្នឹងគេហៅអ្នកថ្មីហើយ!!ភាគច្រើនហើយនឹងភាគច្រើនបើគេដឹងប្រវត្តិរូបរបស់យើងធ្វើទាហាន ធ្វើគ្រូបង្រៀនធ្វើរការអីធំៗដែលនៅសម័យលន់ នល់ ហ្នឹងហាំ!!

កះហ៊ឺៗ!!

ខះ គេយកវ៉ៃចោលហើយ!!

កះ ខ្លាំង!!

ខះហ្នឹងហើយ ហ្នឹងគេហៅខ្មាំងហើយ
ហ្នឹងគេមានបំពាក់សក្ត័បំពេញអីហ្នឹងគេដឹងគេយកទៅវ៉ៃចោលយកទៅអីហើយ!!ឪក្មេកញ៉ុមហ្នឹងគាត់ពាក់សក្ត័ដែរ អ៊ីចឹងបានគេអត់បានវ៉ៃចោលនៅហ្នឹង គាត់បាននាំកូនរត់ទៅបាត់ដំបង
ទៅនៅបាត់ដំបងវិញ!!

កះកុំអោយគេដឹងអីអ៊ីចឹងទៅណាស់!!

ខះ ចាំ!!បំបិតប្រវត្តិរូបគាត់ណាស់!!ដូចគាត់ធ្វើទាហានអ៊ិចឹងគាត់ធ្វើមេដែរ
ហើយគាត់សក្តិពកាលហ្នឹងហ្នំ!!ដល់ហើយគាត់ដឹងខ្លួនគាត់ធ្វើទាហានអ៊ីចឹងគាត់ដឹងថានៅស្រុកហ្នឹងគាត់ដឹងតែស្លាប់ហើយ
ដល់ពេលអ៊ិចឹងគេជំលៀសទៅបាត់ដំបងមួយវគ្គទៀតបងអ្នកណាចង់ទៅទៅណាស់!!អ្នកមានខ្លួនហ្នឹងទៅម៉ង
ម៉ែក្មេកញ៉ុមឪក្មេកញ៉ុមមួយគ្រួសារហ្នឹងទៅបាត់ដំបងទាំងអស់ទៅទៅមានអាបងប្អូនទៅពីស្រុកទៅដឹងថាឪក្មេកញ៉ុមហ្នឹងធ្វើទាហានធ្វើអីអញ្ចឹង គេតាមរាយការណ៍ទៀត
គាត់រត់ទៅថៃហាំឪក្មេកញ៉ុមហាំ!!

កះ រត់ទៅរួចដែរ?

ខះ រត់រួចទៀតទទៅគ្នាពីរនាក់ កាន់ខ្សែគោមួយខ្សែម្នាក់ថាដើររកគោ!!

កះហ្ហ!!!

ខ៖ ដល់ពេលហើយឃើទៅ!!

ក៖ធ្វើរបៀបបោកសិនបញ្ឆោតសិនទៅអ្នកមីងណោះ?

ខ៖ ហ្នឹងហើយ បញ្ឆោតៗទៅ !!

ក៖ចាំ!!

ខ៖គេសួរថាទៅរកគោរកគោអញ្ចឹងទៅណាស់!!
ហើយទៅចូលថៃទៅពីរនាក់គេបាញ់ងាប់ម្នាក់នៅតែឪក្មេកញ៉ុម!!

ក៖អូយ!!

ខ៖
ឪក្មេកញ៉ុមនឹងចេះគ្រូគាត់ខ្លាំងគ្រូគាត់ពូកែហាំ!!គាត់មានគាត់ធ្វើទាហានតាំងពីឥស្សរណោះ!!

ក៖ចាំ!!អញ្ចឹងគាត់ទៅចូលដល់ដីថៃទេអ្នកមីង?

ខ៖ គាត់ទៅដល់ដីថៃ ថៃចាប់ដាក់គុក តែគុកថៃហ្នឹងគុកដេកពូកទេណាស់។

ក៖ចាំ!!

ខ៖ ប្តីញ៉ុមហ្នឹងមុនគាត់ការហ្នឹង គាត់បានទៅដេកជាមួយប៉ាគាត់ហ្នឹងមួយយប់ដេកនៅជំរុំហាំ!!
គាត់ជួបគាត់ដើរជាមួយពួកថៃឪក្មេកញ៉ុមហ្នឹង!!

ក៖ហ៊ឺៗ!!

ខ៖ហើយប្តីញ៉ុមគាត់អង្គុយលក់ម៉ាញ៉េលក់កង់អីហ្នឹង!!ដែលគាត់នៅរកស៊ីនៅអូរហ្នឹង!!ស្រាប់
តែឃើញប៉ាគាត់ដើរជាមួយពួកថៃគាត់ស្រែកហៅប៉ា ប៉ាហ្នឹង
គាត់ងាកមកឃើញកូនហ្នឹងអោបកូនអញ្ចឹងទៅ!!

ក៖ ពេលហ្នឹងបែកហើយហើយហោបានជួបហោ?

ខ៖ ជួបហ្នឹងបែកហើយហើយ ហើយគាត់បបួលប៉ាគាត់អោយមកស្រុកដែរ
ហើយគាត់ថាអញ្ចេកប៉ាគាត់ថាអញខ្លាចអញអត់ហ៊ានទៅទេ គេថាឡានផ្លាស់តែតែកុងទេ!!

កះចាំ!!

ខះគាត់អត់មកហើយបងឯងមើលហើយដល់ពេលគាត់ធ្វើ
គាត់ធ្វើមេអីដែរហ្នឹងហាំតែដូចច្បាប់ព្រៃអញ្ចឹងណាស់
គាំតចាញ់បោកគេគេសម្លាប់គាត់ដែរតើ!!

កះ ហ៊ឺ!!អាខំរត់បានឡើងដល់ណាណីហើយហ្នឹងហាំ!!

ខះ បានរត់រួចហើយ!!អាមកនេះអាបែកយើងមកនៅជំរុំណោះ
ហើយប្ដីញ៉ុមដឹងគាត់ណោះគេចាប់ប៉ាគាត់អញ្ចឹងគាត់រត់មកស្រុកវិញដែរទៅ!!តាមរកគាត់ទៀត
ហាំ តាមរកប្ដីគាត់ទៀតណាស់!!ដឹងថាមានកូននៅហ្នឹង!!

(មិត្តភក្តិ)ះ ពួកថៃមែន?

ខះ ពួកខ្មែរយើងហ្នឹងហាំ!!

កះ ហើយគំនុំអីគេអ៊ំពេលហ្នឹង?

ខះ ដឹងអីគាំតអ្នកធ្វើការដូចគ្នាក្រែងលោគេមានគំនុំអីយើងអត់ដឹងដែរហាំ!!

កះ តែនៅក្នុងអំឡុងប៉ុល ពតហ្នឹងគាត់នៅថៃទេណោះអ៊ិចឹង?

ខះ នៅពេលកំឡុងប៉ុល ពត គេជំលៀសទៅបាត់ជំបងគាត់ទៅរត់ទៅចូលថៃ
គាត់រួចខ្លួនហើយណាស់ តែគាត់ស្លាប់ មកស្លាប់យើង!!

កះ ចូលជំរុំណោះវិញ!!

ខះ មកជំនាន់យើងណោះ យើងបែកវិញហើយហ្នឹង!!បែកពីអាពត គាត់ស្លាប់មុនញ៉ុមការហ្នឹង !

កះបើនៅថៃណោះរហូតទៅអត់អីទេ!!

ខះ នៅថៃមានអី!!

កះ មកមកជំរុំ!!
កំអីហ្នឹងបើសិនជានៅជំរុំហ្នឹងបានទៅស្រុកគេស្រុកអីណាណីឆ្ងាយទៀតហើយ!!!

ខ៖ ស្តាយគាត់គាត់អត់ទាន់បានមកផ្ទះមកអី!!

(មិត្តភក្តិ)៖ ស្តាយគាត់ គាត់មិនទាន់អាយុច្រើនអីណាស់ណាណាហី?

ខ៖ គាត់ប្អូនម៉ែក្មេកញុំមផងហ្នឹង!!

(មិត្តភក្តិ)៖ អាយុប៉ុន្មានកាលស្លាប់ហ្នឹង?

ខ៖ ប្រហែលជាខ្ទង់២៩០ជាង៥០អីហ្នឹងហើយមើលទៅ!!ថាប៉ុណ្ណឹងចុះ!!

(មិត្តភក្តិ)៖ ហ៊ីក្មេង!!

ខ៖ គាត់នៅក្មេងដែរហ្នឹង!!

ក៖ចាំ អញ្ចឹងអ្នកមីងអាពេលស្លាប់នៅកោះគរនេះអត់ដែលមានឃើញណាហី គ្រាន់តែដឹងថាយកទៅហ្នឹងសម្លាប់ហើយ?

ខ៖ ហ៊ីដល់តែពេលយើងបែកហើយយើងឃើញសុទ្ធតែឆ្អឹងម៉ងហាំ!!

ក៖ហ្ហ៎!!

ខ៖ឆ្អឹងហ្នឹង ចេតិយគេយកមកដាក់នៅវត្តឈ្យូងលៀបនេះបង មួយចេតិយនេះពេញ។

ក៖ហ៊ី!!

ខ៖ ឃើញ!!

ក៖ ចាំ!!

ខ៖ជីករណ្តៅដាក់ហ្នឹង!!

ក៖ចាំ!!

ខ៖វាវ៉ៃបញ្ចូលរណ្តៅអញ្ចឹងទៅណាស់!!

ក៖ហ៊ីៗ!!

ខ៖រណ្តៅទៅនាំគ្នាទៅរើសឆ្អឹងទៅ សុទ្ធតែបងប្អូនកូនចៅយើងហើយ ទាំងគេចាប់ទៅគេបាត់ត្រឹមហ្នឹង មកងាប់នៅត្រឹមហ្នឹង!!ហើយនាំគ្នាទៅរើសតែឆ្អឹងមក មិនដឹងជាឆ្អឹងអ្នកណាអ្នកណាទេណាស់!!រើសយកមកដាក់នៅក្នុងវត្តឈ្យូងលៀបហ្នឹងធ្វើបុណ្យ ធ្វើអីរាល់តែនេះហ្នឹង!!

ក៖ ឥឡូវនៅកន្លែងគេនៅកន្លែងគេសម្លាប់អីហ្នឹងមានគេធ្វើ ធ្វើផ្ទះនៅលើអីអស់ហើយហី?

ខ៖ គេធ្វើលើ!!

ក៖ ខ្មោចលែងលងហើយ!!

ខ៖ ខ្មោចលែងលងហើយ!!

ក៖ អូយសាហាវណាស់អ្នកមីងអើយ !!តែដល់ពេលនៅក្នុងភូមិអីនៅកន្លែងធ្វើការអីអត់តមានខ្មោចលងទេអ្នកមីងហេ ដូចថាដើរអីវ៉ាន់ ដូចថាឃើញសាកសពអីវ៉ាន់ហ្នឹងហាំ??

ខ៖ បើសាកសពវាមិនមែនចោលជាលាសជាព្រៃទេ ជីករណ្តៅ ដល់អអញ្ចឹងវាមាននៅក្នុងរណ្តៅណាវានៅក្នុងរណ្តៅហ្នឹងហើយ!!

(មិត្តភក្តិ)៖ នៅតែកោះគរហ្នឹង!!

ខ៖ ចាំ នៅកោះគរហ្នឹងដូចវាជីករណ្តៅមួយអីចឹងណាស់!!វាប្រាប់ថាយកបងឯងទៅវៃចោលយកបងឯងទៅវៃចោល!!

ក៖ចាំ!!

ខ៖យកទៅអូសដាក់នៅរណ្តៅហ្នឹងទៅ !!

ក៖ហ៊ឺៗ!!

ខ៖អញ្ចឹងទៅណាស់ វៃគៀករណ្តៅអីចឹងទៅហើយវៃហើយបញ្ជូនក្នុងរណ្តៅហ្នឹងទៅ !!

(មិត្តភក្តិ)៖ហើយអត់កប់ទេហេ ហើយចុះដាក់បន្ត?

ខ៖ ដូចអត់មានកប់ផង!! ញុំមអត់ដែលទៅជិតទេញុំមឃើញ!!

ក៖ ឃើញទៀត?

ខ៖ ឃើញគេអ្នកទៅ !!

ក៖ហ្ហ៎!!

ខ៖អត់ហ៊ានទៅទេ ញុំមខ្លាចណាស់ ឃើញតែឆ្អឹងគរគ្នាដូចភ្នំហ្នឹង!!

ក៖ នៅម្តុំណាទៅវិញទៅអ្នកមីង?

ខ៖ នៅកោះគរយើងហ្នឹង!!

(មិត្តភក្តិ)៖ នៅកោះគរ!!

ក៖ ហើយចុះដល់ពេលបែកហើយមីងមានដែលឆ្លងទូកទៅមើលពេលហ្នឹងទៅមើលគំនរ?

ខ៖ ញុំមមិនទៅទេ ញុំមអត់ហ៊ានមើល គេអ្នកទៅមើលគេឃើញឆ្អឹងនៅគរគ្នាហ្នឹងទៅ!!

ក៖ហ្នឹងហើយពូផល្លីនិយាយទៅមើលឃើញនៅហ្នឹងហ្ហ៎!!

ខ៖ចាំ!!

ក៖ គាត់អ្នកប្រាប់ញុំម!!

ខ៖ គេទៅមួយគំនរគ្នាហ្នឹង អត់ទៅតែញុំមទេញុំមអត់ហ៊ានមើល!!

ក៖ ដូចរបៀបថាខ្លាច ដូចថានឹកឃើញអារឿងពេលមុន!!

ខ៖ គេអ្នកទៅគេទៅនាំគ្នារើសឆ្អឹងយកមកគរនៅចេតិយនៅវត្តហ្នឹង!!

ក៖ចាំ!!

ខ៖ជញ្ជូនឆ្អឹងយកមក!!

ក៖ ហ្នឹងហើយតារាចំរៀង គង់ សំអឿនអីវ៉ាន់ហ្នឹងម៉ែនិយាយថានៅហ្នឹងអញ្ចឹង!!

(មិត្តភក្តិ)៖គង់ សំអឿនអីគេសម្លាប់នៅហ្នឹង នៅអាពតហ្នឹង!!

ខ៖ ហ្នឹងហើយនៅហ្នឹង ប៉ុនឥឡូវហ្នឹងឆ្អឹងអីគេប្រមូលមកអស់ហើយ!!

ក៖ ចាំ!!អ្នកមីងពេលបែកពីសង្គ្រាមមកអារម្មណ៍ម៉េចដែរមួយៗធូរក្សាក្តអស់ហើយហោ?

ខ៖សប្បាយ សប្បាយចិត្តម៉ងគ្រប់គ្នា
បងអើយគ្រាន់តែថាបែកភ្លាមមកហាំទាំងអស់គ្នាសប្បាយដល់ហើយទាំងអស់គ្នា!!

(មិត្តភក្តិ)៖ ហ្នឹងហើយ!!

ខ៖ ចុះយើងកាលហ្នឹងបែកមកភ្លាម គេចូលដល់ភ្នំពេញគេថាបែកហើយនោះ!!

(មិត្តភក្តិ)៖ មានសេរីភាព!!

ខ៖ មានសេរីភាពម៉ង!!

ក៖ គេប្រកាសម៉ងមីងហោ?

ខ៖ ចាំគេប្រកាសហាំ គេប្រកាសហើយគេច្រៀងនៅក្នុងហ្នឹង !!

ក៖ហ៊ឺ!!

ខ៖យើងមានតែរិតយោងទេកាលហ្នឹងហ្នំ!!

ក៖ ហើយអញ្ចឹងពួកអាទព័ប៉ុល ពតហ្នឹងទៅណាអស់ទៅអ្នកមីង?

ខ៖ ខ្មែរក្រហមហ្នឹងវាទៅព្រៃខ្លះទៅ អាខ្លះក៏វាចូលខ្មែរដូចតែគ្នាវា អាខ្លះវាឈប់ទៅ!!

ក៖ អាខ្លះធ្វើមនុស្សធម្មតាទៅ?

ខ៖ ហ្នឹងហើយ
វាធ្វើមនុស្សធម្មតាជាមួយយើងដែរទៅរកប្រពន្ធរកកូនរស់នៅតាមធម្មតាហ្នឹងវិញទៅ
ហើយអាអ្នកខ្លះអ៊ីចឹងទៅ វានៅតស៊ូអ៊ិចឹងទៅវាចេះតែទៅនៅភ្នំនៅអីអញ្ចឹងទៅទ័ព
សម្តេចគេប្រកាសអោយចូលមកហ្នឹងបានអាពតបានខ្មែរក្រហមអត់ទៅ
ឥឡូវវាមានខ្មែរក្រហមណាទៀតបើវាចូលមកយើងអស់ដែរ!!

ក៖ចាំ!!

ខ៖ជាមួយតែគ្នាអស់ហើយ!!

ក៖ចាំ!!

ខ៖ខ្វះអីទាហានខ្មែរក្រហមមួយគំនរគ្នា។

ក៖ អ្នកមីងមានស្គាល់អ្នកណាគេដែលនៅទាល់តែឥឡូវហ្នឹងទេ?

ខ៖ ទាហានខ្មែរក្រហមហោ?

ក៖ហ្នឹងហើយអ្នកដែលសម្លាប់គេអញ្ចឹងទៅណាស់!!

ខ៖ ហ្ន៎មានតើ អ្នកឃើញនៅតែហ្នឹង អ្នកខ្លះគេក៏សម្លាប់វិញអញ្ចឹងទៅ ខ្លះគេសម្លាប់វិញទៅ ខ្លះគេនៅចំស្រុកភូមិយើងស្លូតៗអីចឹងអត់សម្លាប់វិញទេ។

ក៖ ហើយដល់ពេលហើយស្គាល់មុខដែរហោ?

ខ៖ ស្គាល់!!

ក៖ តែដល់ពេលហើយកែប្រែខ្លួនទេមីង ធម្មតាដូចយើងទន់ភ្លន់អីវ៉ាន់អញ្ចឹងមក?

ខ៖ អ្នកខ្លះគេយកបងប្អូនគេទៅអញ្ចឹងទៅ ដូចថាយើងឃើញធ្វើមេកងអញ្ចឹងទៅណាស់ ហើយយើងឃើញយកប្ដីបងឯងទៅអញ្ចឹងណាស់!!ដល់ពេលឥឡូវបងឯងឃើញមុខក៏បងឯង នៅតែឈឺចាប់ដែរ ឃើញមុខវានោះ!!

(មិត្តភក្តិ)៖ ហ្នឹងហើយ។

ខ៖នៅតែស្អប់អញ្ចឹង យើងហាំហើយបើវាធ្វើមិនដឹងអីអញ្ចឹងទៅ!!

ក៖ហ៊ឺៗ!!

ខ៖ថាយើងនៅតែឈឺចាប់អីចឹងហាំ!!ដែលយកប្ដីយើងទៅសម្លាប់ចោលអញ្ចឹងណាស់!!

ក៖ តែវាក៏មិនដេកលក់ស្រួលដែរដល់ពេលឥឡូវហើយហ្ន៎!!

ខ៖ ហ៊ីដូរស្រុកអស់ហើយហ្នឹងពួកហ្នឹងហ្នំ!!

ក៖ហ៊ីៗ!!

ខ៖អាអ្នកដែលខ្លាំងៗយកគេទៅវ៉ៃចោល ហ្នឹងជូនកាលវាដំបូងវានៅហ្នឹង
ដល់ហើយវាឥឡូវវាទៅនៅកោះធំ ព្រៃកអំបិលអីចឹងទៅណាស់បង
វាមិនសូវហ៊ាននៅស្រុកហ្នឹងណា!!មកលេងម្តងម្កាលអីចឹងទៅ!!

(មិត្តភក្តិ)៖ មកលេងម្តងម្កាលភ័យទៀតហ្នឹងហាំ!!

ក៖ខ្លាចគេវ៉ៃ!!

ខ៖ មកម្តងម្កាលភ័យទៀតហាំវាមានខ្លួនហ្នំ!!

ក៖អីចឹងអ្នកមីងដល់ពេលអីចឹងធូរអស់រលីងហើយណោះ ដល់ពេលបែកពីជំនាន់ប៉ុល
ពតអីវ៉ាន់វិញមក?

ខ៖ ចាំធូរហើយ!!

ក៖ អ្នកមីងរកស៊ីអីគេដែរ?

ខ៖ ឥឡូវហ្នឹងមែន?

ក៖ចាំ!!

ខ៖ឥឡូវហ្នឹងរកស៊ីដាំអីៗយកទៅលក់ផ្សារអញ្ចឹងទៅទៅទិញគេខ្លះអីខ្លះអញ្ចឹងទៅ!!

ក៖ ចាំ!!អញ្ចឹងឥឡូវដាំផ្ទីនៅផ្ទះ?

ខ៖ចាំ!!

ក៖ដល់ពេលកាត់មក យកទៅអោយម៉ូយគេមកយកឬក៏យកទៅអោយគេនៅផ្សារ?

ខ៖ យកទៅលក់ខ្លួនយើងនៅផ្សារ!!

ក៖ហ្នំ!!

ខ៖ផ្សារតាខ្មៅអិចឹង!!

ក៖ លក់ដល់អស់ដល់យប់បានមកផ្ទះវិញទៅ?

ខ៖ ចាំអោយតែម៉ោង១១ទៅហើយ។

ក៖ហ្ហ៎!!ហាទៅលក់ពេលយប់វិញ?

ខ៖ចាំ!!លក់អោយយើងបោះម៉ូយគេអ្នកទៅទិញយើងយកទៅគ្រប់ផ្សារ!!

ក៖ហ្ហ៎!!

ខ៖ខ្លះទៅផ្សារច្បារអំពៅ ខ្លះទៅផ្សារដើមគរ ខ្លះទៅផ្សារជម្ពូវន័!!

ក៖ចាំ!!

ខ៖ខ្លះទៅគេមកទិញហ្នឹងមូលតើ!!

ក៖ចាំ!!

ខ៖ទិញលក់ដើរតាមផ្សាររៀងៗខ្លួនទៅណាស់!!

ក៖ចាំ!!

ខ៖ហើយយើងយកទៅបោះម៉ូយមកយកត្រឹមហ្នឹងទៅ!!

ក៖ ចាំអិចឹងរកស៊ីបានកាកកបគ្រាន់បើដែរ គ្រាន់បានមួយទប់ៗអីចឹងទៅណោះ?

ខ៖ ម៉ាទប់អាចចិញ្ចឹមជីវិតហ្នឹងវាបាន វាមិនអត់ទេ ក៏វាមិនមានអីពេកដែរ ចាំឥឡូវនៅធ្វើការកើតដល់ពេលតិចទៀតទៅមិនដឹងយ៉ាងម៉េចទេ!!!តិចទៀតធ្វើការរកស៊ីលែងកើតហើយអាហ្នឹងចាំគិតទៀតទៅណាស់!!

ក៖ចាំហ្នឹងហើយ មានកូនមានអីមើលវិញម្តងអីចឹងទៅ!!

ខ៖ចាំ!!

កៈតែញ៉ុមគិតថាទោះតែរៀងចំណាស់ៗទៅ
នៅផ្ទះអីវ៉ាន់មានតែដកូនយកទៅលក់អោយអីបានកើត!!

ខៈចាំ!!

កៈចាំ!!

ខៈអ្នកមីងដាំនៅហ្នឹងផ្ទះ!!

កៈ អញ្ចឹងអ្នកមីងមួយនេះគឺជាសំនួរមួយចុងក្រោយ
តើអ្នកមីងមានពាក្យពេចន៍អីគេខ្លះដែលចង់ផ្ដែផ្ដាំទៅកាន់កូនចៅថាអោយគាត់ដើរលើផ្លូវម៉េច ដែរ ថាអោយគាត់ជៀសពីផ្លូវម៉េចដែរអញ្ចឹងណាស់?

ខៈ នៅក្នុងចិត្តញ៉ុមរាល់ថ្ងៃចេះតែអប់រំកូនដែរ
ចង់អោយកូនហ្នឹងហាំដើរតាមផ្លូវល្អកុំអោយធ្វើអ្វីដែលខុសហ្នឹងច្បាប់ ហើយខុសមិនសាកសម
ចង់អោយកូនហ្នឹងដើរទៅតាមផ្លូវដែលយើងដើរដែរសព្វថ្ងៃហ្នឹងហាំ!!

កៈចាំ!!

ខៈ
តែដឹងគេដល់ថ្ងៃណាខែណាពេលណាបានគេភ្ញាក់រលឹកដើរលើផ្លូវទៅជាមួយយើងទេណាស់!!

កៈ អ្នកមីងបានប្រាប់ដែរហោ?

ខៈ ប្រាប់!!

កៈចាំ!!

ខៈប្រាប់បបួលគេដែរតើ អាពៅហ្នឹងក៏ញ៉ុមបបួលដែរ!!ចង់ទិញម៉ូតូ
ហ្បែងទិញទិញទៅតែចូលសាសនាគ្រិស្ដជាមួយម៉ែទៅម៉ែទិញអោយ!!ញ៉ុមថាញ៉ុមចូលទិញអោយញ៉ុមមកញ៉ុមចូល!!

កៈ ហ្នំសុទ្ធតែអញ្ចឹងទៀត!!

ខៈ សុទ្ធតែអញ្ចឹងហាំ!!!ដល់ឥឡូវទិញអោយហើយធ្វើព្រងើយ!!

កៈ ដោយសារមិនមែនចង់លួងចិត្តអីទេ ដោយសារចង់អោយកូនដើរលើផ្លូវល្អ!!

ខៈ ចង់អោយកូនដើរតាមផ្លូវល្អ កូនទាំងអស់ហ្នឹងញ៉ុមចេះតែនិយាយទៅ
ម៉ែទៅហើយកូនអើយទៅទៅហីទៅជាមួយម៉ែទៅទៅវិហារជាមួយម៉ែទៅ
ពេលយើងទៅទៅដូចជាយើងទៅរក្សាសីលសុំសីលដែរ
យើងទៅរៀនសូត្រទៅចេះដឹងទប់អារម្មណ៍
អារម្មណ៍ដែលក្នុងចិត្តយើងមួម៉ៅក្តៅក្រហាយភ្លើងនៅក្នុងខ្លួនយើងអាចពន្លត់បានបងណាស់!!

កៈហ្នឹងហើយ!!

ខៈ
យើងដឹងហាំយើងរៀនសូត្រដឹងទៅយើងអាចពន្លត់ភ្លើងនៅក្នុងខ្លួនបានយើងអាចទប់អារម្មណ៍
បាន ញ៉ុមហាំកាលពេលមិនទាន់ចូលហាំ ថាញ៉ុមខឹងកូន
ថាញ៉ុមជេរអោយឡើងមួយទំហឹងៗណាស់បង!!
ដល់ពេលឥលូវញ៉ុមចូលសាសនាយើងទៅហាំ ពេលដែលញ៉ុមចង់ជេរ
វាទ្រាំអត់បាននៅពេលដែលវាធ្វើខុសហាំ ជេរតែមួយមាត់នឹកឃើញតែម្តង
ជេរតែមួយម៉ាត់ជេរទៀតដូចថាទៅលែងរួចម៉ងៗ!!មែនហាំពេលមុនជេរ២០ម៉ាត់ដល់ពេលឥឡូ
វជេរត្រឹម១ម៉ាត់អីហ្នឹងនឹកឃើញភ្លាមម៉ង!!

កៈ នឹកឃើញថាលែងចង់ធ្វើវិញម៉ង!!

ខៈ នឹកឃើញថាខុស ជេរវាបាបឯងទៀតហ្នឹងហាំ
ពួកអស់នេះធ្វើអោយឯងជេរវាអោយឯងបាបទៀតហាំ!!ដល់ពេលអញ្ចឹងនឹកឃើញជេរ
ជេរតែមួយម៉ាត់ពីរអើ យើងអានេះក្នុងចិត្តញ៉ុមទេ ក្នុងចិត្តញ៉ុមចង់អោយកូនផ្លូវល្អ
ការពិតចង់អោយកូនចូលក្នុងព្រះយេស៊ូវជាមួយគ្នាណាស់បងណាស់!!

កៈចាំ!!

ខៈក្រែងថ្ងៃណាវាភ្ញាក់រលឹកបានចូល ញ៉ុមសង្ឃឹមថាថ្ងៃក្រោយគេនឹងទៅតាមយើងហាំ!!

(មិត្តភក្តិ)ៈ ឥឡូវមិនទាន់ដឹងមិនទាន់យល់!!

ខ៖ ចាំ!!ចេះតែព្យាយាមដែរ ចេះតែព្យាយាមអោយកូនចូលហ្នឹង
ញ៉ុមដឹងថាបើកូនបានចូលវាល្អ!!

ក៖ហ៊ឺៗ!!

ខ៖យើងហ្នឹងក៏វាលែងសូវបារម្ភហាំ!!

ក៖ ហ្នឹងហើយ!!

ខ៖ វាអត់ចូលវានាំគ្នាទៅផឹកស៊ីផឹកស៊ីហ្នឹង ហើយបើវាចូលតាមយើងអញ្ចឹងទៅ វាមិនផឹក
តែផឹកស៊ីវាច្រើនតែមានរឿង ផឹកទៅមនុស្សចេះតែស្រវឹងទៅវាចេះតែមានបញ្ហាហើយ!!

(មិត្តភក្តិ)៖ ចូលហើយក៏វាមិនទាន់ផ្តាច់បានដែរតែវារៀនយូរៗវាដឹងវាផ្តាច់បានម៉ង!!

ខ៖ ចាំ!!

ក៖ ចាំហ្នឹងហើយ!!អញ្ចឹងអ្នកមីងមានអីបន្ថែមទៀតទេ?

ខ៖ វាបន្ថែមថាថ្ងៃក្រោយទៅញ៉ុមសង្ឃឹមថាកូនញ៉ុមហ្នឹងដើរតាមផ្លូវល្អរបស់ព្រះអង្គហាំ!!

ក៖ចាំ!!

ខ៖ចាំ!!អរគុណសហរដ្ឋអាមេរិចដែលគេជួយយើង!!

ក៖ ដើម្បីបង្កើតប្រវត្តិឡើងវិញ!!

ខ៖ ហ្នឹងហើយបង្កើតប្រវត្តិហ្នឹង!!

ក៖ទុកអោយកូនចៅជំនាន់ក្រោយស្តាប់!!

ខ៖ ទុកអោយកូនចៅជំនាន់ក្រោយស្តាប់អីចឹង ញ៉ុមអរគុណគាត់សហរដ្ឋអាមេរិចធំៗ!!

ក៖ហ្នឹងហើយចាំអីចឹងអរគុណច្រើនអ្នកមីងដែលអោយញ៉ុមបានសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីង
អញ្ចឹងអ្វីទាំងអស់កូនចៅរបស់អ្នកមីងគាត់នឹងបានស្តាប់ហើយនឹងបានរៀនក៏ដូចជាបានដឹងពីជីវិតរបស់អ្នកមីងឆ្លងកាត់អីគេខ្លះអញ្ចឹងណាស់អ្នកមីង!!

ខ៖ ចាំ!!

ក៖ ចាំអរគុណ។